ISSN 1560-7615

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី៩ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៥ | តម្លៃ ១.៥០០៛

# ដំណើរការកសាងប្រព័ន្ធតាមដានភាពក្រីក្រផ្អែកលើសហគមន៍នៅកម្ពុជា

**លោក នូ កែវសុទ្ធា និង ច័ន្ទ សុផល បានបង្ហាញពីសារៈសំខាន់នៃប្រព័ន្ធតាមដានភាពក្រីក្រផ្អែកលើសហគមន៍ សំរាប់តាមដានការកាត់បន្ថយភាពក្រីក្រក្នុងមូលដ្ឋាន ដោយសង្កត់ធ្ងន់លើការ កសាងស្ថាប័ន និងសមត្ថភាពនៅកំរិតមូលដ្ឋាន ។***



*ការនេសាទ គឺជាប្រភពចំណូលមួយរបស់ប្រជាជនជនបទ ។*
*ចំណូល គឺជាអាំងឌីកាទ័រ CBPMS មួយសំរាប់ត្រួតពិនិត្យភាពក្រីក្រ ។*

ប្រទេសកម្ពុជា បានប្ដេជ្ញាអនុវត្តដំណើរការធ្វើវិមជ្ឈការដ៏វែងឆ្ងាយ ។ ក្នុងនេះ មានការទទួលស្គាល់ជាទូទៅពីសារៈសំខាន់នៃអភិបាលកិច្ចនៅមូលដ្ឋាន ហើយមានច្រើនស្ថាប័នកំពុងធ្វើការងារ ដើម្បីញ៉ាំងឱ្យកំណែទំរង់នេះកាន់តែបានជោគជ័យ ។ ក្រុមប្រឹក្សាឃុំ ត្រូវតែមានប្រភពព័ត៌មានដ៏ទៀងទាត់ និងអាចទុកចិត្តបាន ដើម្បីអាចកំណត់ពីតំរូវការផ្សេងៗ កសាងផែនការ ធ្វើការតាមដាន និងវាយតំលៃលើគំរោងអភិវឌ្ឍន៍នានាមានប្រសិទ្ធិភាពល្អ ។ ប្រព័ន្ធតាមដានភាពក្រីក្រផ្អែកលើសហគមន៍ (CBPMS) ដែលបានដាក់អនុវត្តសាកល្បងនៅកម្ពុជា មានគោលដៅផ្ដល់ឱ្យក្រុមប្រឹក្សាឃុំនូវទិន្នន័យជាក់ស្ដែងស្ដីពីតំរូវការទាំងនេះ ហើយក្នុងរយៈពេលវែងនឹងបង្កើតប្រព័ន្ធមានចិរភាពមួយសំរាប់តាមដានការកាត់បន្ថយភាពក្រីក្រពីមួយឆ្នាំទៅមួយឆ្នាំ ។ ដូច្នេះហើយ គំរោងនេះសង្កត់ធ្ងន់លើការកសាងស្ថាប័ន និង សមត្ថភាពនៅកំរិតមូលដ្ឋាន ។

ពីខែតុលា ២០០៣ ដល់ វិច្ឆិកា ២០០៤ មានការធ្វើអង្កេតលើ ១១.៩៣៧ គ្រួសារក្នុង ៦ឃុំ នៅខេត្តបាត់ដំបង និងក្រចេះ ។ គ្រួសារទាំងនោះ តំណាងឱ្យ ២ស្រុក ដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ផ្ទុយស្រឡះពីគ្នា ។ សំរាប់ការធ្វើជំរឿននៅកំរិតឃុំ អ្នកភូមិដែលមានចំណេះដឹងគួរសមត្រូវបានជ្រើសរើស និងបណ្ដុះបណ្ដាល ឱ្យធ្វើអង្កេតតាមគ្រួសារដោយផ្អែកលើបញ្ជីសំណួរមួយមាន ៥ទំព័រ ។ ការចាត់ចែងទិន្នន័យ គឺធ្វើឡើងដោយដៃ នៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ និងការត្រួតពិនិត្យបច្ចេកទេសរបស់ក្រុមពិនិត្យតាមដានគំរោង ។ ជាលទ្ធផល ឃុំទាំង៦ អាចចងក្រងសៀវភៅស្ថិតិភាពក្រីក្ររបស់ខ្លួនបាន សំរាប់បំរើដល់ការធ្វើផែនការ និងការតាមដានភាពក្រីក្រ ។ ការសិក្សាបានពិនិត្យពីអាំងឌីកាទ័រ CBPMS ផ្សេងៗដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពច្រើនបែបយ៉ាងនៃភាពក្រីក្រៈ ប្រជាសាស្ត្រ ការអប់រំ ផ្ទះសំបែង និងជីជ្ជី សុខភាព ចំណូលចំណាយ ទ្រព្យសម្បត្តិ អំពើហិង្សា សន្តិសុខ និង សណ្ដាប់ធ្នាប់ ។ ប៉ុន្តែក្នុងឯកសារនេះ បង្ហាញចំណុចសំខាន់ពីវិធីសាស្ត្រសំរាប់ការអនុវត្តគំរោង និលទ្ធផលខ្លះស្ដីពីអត្រាភាពក្រីក្រ ។

* អត្ថបទនេះផ្អែកលើរបាយការណ៍បច្ចេកទេសមួយដែលបានបង្ហាញក្នុងសិក្ខាសាលាស្ដីពីប្រព័ន្ធតាមដានភាពក្រីក្រផ្អែកលើសហគមន៍ (Community-Based Poverty Monitoring System: CBPMS) សំរាប់កម្ពុជា ធ្វើឡើងនៅភ្នំពេញថ្ងៃ១៨ វិច្ឆិកា ២០០៤ ក្រោមការឧបត្ថម្ភមូលនិធិពីមជ្ឈមណ្ឌលធនធានអភិវឌ្ឍន៍អន្តរជាតិកាណាដា IDRC ។

## មាតិកា

ដំណើរការកសាងប្រព័ន្ធតាមដានភាពក្រីក្រផ្អែកលើសហគមន៍នៅកម្ពុជា ......១
ឈានពីការកសាងសន្តិភាពទៅដល់សន្តិសុខមនុស្ស? ...... ៥
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស ...... ៨
— ស្ថានភាពក្នុងប្រទេស ...... ១០
— សន្ទស្សន៍សេដ្ឋកិច្ច ...... ១៣
ព័ត៌មានថ្មីៗពី វបសអ ...... ១៦

## បញ្ហាផ្សេងៗក្នុងការស្រាវជ្រាវ

CBPMS នឹងជួយបំពេញបន្ថែមដល់វិមជ្ឈការ ព្រមទាំងរួមចំណែកញ៉ាំងឱ្យប្រព័ន្ធវិមជ្ឈការថ្មីរបស់រដ្ឋដំណើរការបានជោគជ័យ ។ កម្ពុជា ពុំមានប្រព័ន្ធតាមដានភាពក្រីក្រផ្អែកលើសហគមន៍ទេ ថ្វីបើមានទិន្នន័យកំរិតភូមិដែលប្រមូលបានតាមរយៈរបាយការណ៍រដ្ឋបាលនៅក្នុងកម្មវិធី Seila/PLG ក្ដី ។ ដើម្បីនឹងកំណត់ពីតំរូវការធ្វើផែនការ ធ្វើការតាមដាន និងវាយតំលៃលើគំរោងអភិវឌ្ឍន៍នានា គេត្រូវកសាងប្រព័ន្ធមួយ និងតំរូវឱ្យក្រុមប្រឹក្សាឃុំអនុវត្តវាឱ្យបានទៀងទាត់និងមានភាពរលូន ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីការិយាល័យស្ថិតិខេត្ត និងស្ថាប័នផ្សេងទៀត ។

ច្បាស់ហើយ កាលណាអ្នកមូលដ្ឋានមានសមត្ថភាពទទួលយក CBPMS ទៅ អនុវត្ត គឺវាមានប្រសិទ្ធភាពចំណាយ ជាងការបញ្ជូនអ្នកធ្វើអង្កេតទៅពីភ្នំពេញ ដូចដែលកំពុងអនុវត្តសព្វថ្ងៃនៅក្នុងអង្កេតកំរិតជាតិ និងអង្កេតផ្អែកលើសហគមន៍ផ្សេងៗ ។ ការចូលពាក់ព័ន្ធ និងការទទួលខុសត្រូវរបស់ថ្នាក់មូលដ្ឋាននៅក្នុងអង្កេត នឹងជួយបង្កើនការប្រើប្រាស់ទិន្នន័យ និងភាពជាម្ចាស់នៅក្នុងមូលដ្ឋាន ។

## គោលដៅជាក់លាក់មួយចំនួនរបស់ CBPMS សាកល្បង:

- ជ្រើសរើសអាំងឌីកាទ័រសមស្របមួយចំនួន សំរាប់ការតាមដានភាពក្រីក្រផ្អែកលើសហគមន៍ និងការធ្វើវិភាគ
- ផ្ដល់ទិន្នន័យជាក់ស្ដែងដែលប្រមូលបានតាមលក្ខណៈវិទ្យាសាស្ត្រ ទៅឱ្យក្រុមប្រឹក្សាឃុំសំរាប់ប្រើក្នុងការធ្វើផែនការ ការតាមដាន និងការវាយតំលៃលើគំរោងអភិវឌ្ឍន៍នានា
- កសាងរបាយការណ៍តាមដានភាពក្រីក្ររបស់សហគមន៍ដោយផ្អែកលើលទ្ធផល CBPMS
- កសាងសមត្ថភាពក្រុមប្រឹក្សាឃុំជ្រើសរើសសាកល្បងក្នុងវិធីធ្វើអង្កេត និងក្នុងការចាត់ថែង ការវិភាគ និងការប្រើប្រាស់ទិន្នន័យ
- បង្កើន និងពង្រឹងចំណងទាក់ទង រវាងការធ្វើផែនការនៅកំរិតឃុំ និងកំរិតខេត្ត/ជាតិ ។

> *កាលណាអ្នកមូលដ្ឋានមានសមត្ថភាពទទួលយកប្រព័ន្ធតាមដានភាពក្រីក្រដោយផ្អែកលើសហគមន៍ (CBPMS) ទៅអនុវត្តនោះគឺធ្វើឱ្យការចំណាយមានប្រសិទ្ធភាពជាងការបញ្ជូនអ្នកប្រមូលពត៌មានមកពីភ្នំពេញ ។*
> *ម្យ៉ាងទៀត ការរួមបញ្ចូលអ្នកនៅមូលដ្ឋានឱ្យជួយប្រមូល និងវិភាគពត៌មាន គឺវាជំរុញឱ្យអ្នកមូលដ្ឋាន មានភាពជាកម្មសិទ្ធិ និងប្រើប្រាស់ទិន្នន័យបានល្អ ។*

## វិធីសាស្ត្រ

### *២.១ ផែនការសំរាប់កសាង CBPMS*

គំរោងនេះមានពីរដំណាក់កាល អនុវត្តក្នុងរយៈពេល ១៧ខែ ។ ដំណាក់កាលទី១ មានរយៈ ៥ខែ ចាប់ពីថ្ងៃ ១ សីហា ដល់ ៣១ ធ្នូ ២០០៣ ហើយដំណាក់កាលទី២ ដែលជា CBPMS សាកល្បង មានរយៈ ១២ខែ ចាប់ពីថ្ងៃ ១ មករា ដល់ ៣១ ធ្នូ ២០០៤ ។CBPMS មានចំណែកផ្សេងៗដូចតទៅ:

### ការជ្រើសរើសរកទីកន្លែង

ឃុំចំនួន ៦ (ប្រហែល ១២.០០០គ្រួសារ) ក្នុង ២ខេត្ត ត្រូវបានជ្រើសយកជាកន្លែងធ្វើ CBPMS សាកល្បង ។ ឃុំ ៣ គឺព្រែកណ្ដៀវិន សំរោងក្នុង និងព្រែកហ្លួង បានជ្រើសយកក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង សំរាប់តំណាងឱ្យតំបន់ធូរធារ ហើយឃុំ ៣ទៀតគឺ ស្នួល ក្សែម និង ស្រែចារ បានជ្រើសយកក្នុងស្រុកស្នួល ខេត្តក្រចេះ សំរាប់តំណាងឱ្យតំបន់ក្រីក្រ ។ បាត់ដំបងគឺជាខេត្តដែលបានទទួលជំនួយបរទេសជាហិរញ្ញវត្ថុ និងការកសាងសមត្ថភាពបានច្រើនគួរសមក្នុង ១០ឆ្នាំកន្លងទៅ រីឯក្រចេះស្ថិតក្នុងចំណោមខេត្តនានាដែលនៅដាច់ស្រយាល និងក្រីក្រជាងគេ ។ លក្ខណៈខុសគ្នាបែបនេះអាចជួយផ្ដល់គំនិតថា តើ CBPMS អាចអនុវត្តយ៉ាងដូចម្ដេចបាននៅក្នុងតំបន់ដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចក្រីក្រ រឺធូរធារ ។ ដូចការរំពឹងទុក ឃុំនានានៅបាត់ដំបង អនុវត្តភារកិច្ចផ្សេងៗបានរលូនល្អជាង ឃុំនានានៅក្រចេះ ។ នៅបាត់ដំបង ការជ្រើសរើស អ្នកធ្វើអង្កេតដែលមានសមត្ថភាពគួរសម គឺមានការងាយស្រួល ប៉ុន្តែនៅក្រចេះ គេលំបាកនឹងរកបានអ្នកធ្វើអង្កេត ដែលមានចំណេះដឹងគ្រប់គ្រាន់ និងចង់ធ្វើការងារនេះ ។ ឃុំនានានៅក្រចេះ នៅដាច់ស្រយាល និងមានផ្លូវតភ្ជាប់យ៉ាងលំបាក ដូច្នេះអ្នកធ្វើអង្កេតត្រូវអស់សោហ៊ុយច្រើនជាងក្នុងការធ្វើដំណើរ ។ ក្នុងបញ្ជីសំណួរដែលបំពេញហើយ គេឃើញមានកំហុសនៅក្រចេះ ច្រើនជាងនៅបាត់ដំបង ។

### ការជួបទាក់ទង: ការជួបជាមួយស្ថាប័នជាប់ទាក់ទិន

មន្ទីរផែនការក្នុងខេត្តទាំងពីរ បានបង្ហាញការយកចិត្តទុកដាក់ចង់បញ្ចូល CBPMS ទៅក្នុងរចនាសម្ព័ន្ធ និងកម្មវិធីជាធម្មតារបស់ខ្លួន និងចង់បង្កើតការិយាល័យខេត្តសំរាប់ចាត់ចែងទិន្នន័យតាមកុំព្យូទ័រ ពីព្រោះគំរោងនេះ ស្របគ្នានឹងផែនការជាតិ ដែលសំដៅពង្រឹងប្រព័ន្ធស្ថិតិតាមមូលដ្ឋាន ។NIS ក៏បញ្ជាក់ពីបំណងចង់បន្តកម្មវិធីសាកល្បងនេះទៅមុខ និងពង្រីកវាជាបណ្ដើរៗនៅក្នុងប្រទេស ហើយរឿងនេះនឹងបង្កើនលទ្ធភាពមាន CBMPS ក្នុងទូទាំងប្រទេស ។ ក្នុងនេះមានការសង្ឃឹមថានឹងអាចកេណ្ឌប្រមូលធនធានថែមពីស្ថាប័នផ្សេងៗទៀតដើម្បីពង្រីកប្រព័ន្ធ ។

### ការកសាងអាំងឌីកាទ័រតាមដានភាពក្រីក្រ

ឆ្លងតាមការពិគ្រោះយោបល់ជាមួយស្ថាប័នដៃគូ និងការសិក្សាលើឯកសារពិភាក្សារបស់ពួកគេ អាំងឌីកាទ័រស្នូលមួយសំណុំត្រូវបានកសាងឡើងដែលទាក់ទងនឹងប្រជាសាស្ត្រ ការអប់រំ ផ្ទះសំបែង ដី ទឹក សុខភាព ចំណាយតាម គ្រួសារ មុខរបរនិងចំណូល ទ្រព្យសម្បត្តិ សត្វចិញ្ចឹម និងអំពើហិង្សាក្នុងគ្រួសារ ។ អថេរមួយចំនួនអាចជាន់គ្នាជាមួយ អថេរដែលមានរួចហើយនៅក្នុងសៀវភៅទិន្នន័យភូមិសិលាដែលបំពេញដោយមេភូមិ ។ ដោយសារ CBPMS ប្រើវិធីសាស្ត្រធ្វើជំរឿន និងដោយអថេរខាងលើ មានសារៈសំខាន់ជាគន្លឹះ ដូច្នេះ អថេរទាំងនេះ ក៏ត្រូវបានរក្សាទុកនៅក្នុងសំណុំអាំងឌីកាទ័រស្នូល ។ ទិន្នន័យទាំងពីរសំណុំ អាចយកមកប្រៀបធៀប និងផ្ទៀងផ្ទាត់ជាមួយគ្នាបាន ដើម្បីកែលំអគុណភាព ។ បន្ទាប់មក បញ្ជីសំណួរមួយក៏បានកសាងឡើងដោយផ្អែកលើសំណុំអាំងឌីកាទ័រស្នូលនេះ ។ ម្យ៉ាងទៀត មានកំហិតច្រើនណាស់នៅលើចំនួន និងលក្ខណៈស្មុគស្មាញនៃបញ្ជីសំណួរ ពីព្រោះទិន្នន័យត្រូវចាត់ចែងដោយដៃ ហើយសមត្ថភាព និងបទពិសោធន៍របស់អ្នកធ្វើអង្កេតនៅមូលដ្ឋាន ក៏មានកំរិតដែរ ។

### *២.២ ការកសាងឧបករណ៍សំរាប់ប្រមូល និងចាត់ចែងទិន្នន័យ*

**ការកសាងបញ្ជីសំនួរកំរិតគ្រួសារ ភូមិ និងឃុំ**

វិធីសាស្ត្រមានការចូលរួម បានយកមកប្រើប្រាស់ដើម្បីកសាងឧបករណ៍សំរាប់ប្រមូល និងចាត់ចែងទិន្នន័យ ហើយបញ្ជីសំណួរមួយក៏ត្រូវបានកសាងដាក់ប្រើសាកមើលមុន និងកែសំរួលឡើងវិញ ដោយមានការពិគ្រោះយោបល់ជាប់រហូតជាមួយក្រុមប្រឹក្សាឃុំ ។

**ការដាក់ប្រើសាកមើលមុន**

យោងតាមការពិភាក្សានៅខែវិច្ឆិកា ២០០៣ ជាមួយអ្នកដឹកនាំបណ្ដាញ CBPMS, គំរោងបានដាក់ប្រើសាកមើលមុននូវឧបករណ៍ស្រាវជ្រាវមួយចំនួន ថ្វីបើរឿងនេះមិនបានគ្រោងពីដំបូងក្ដី ។ ដោយសារវាជាការសាកមើលដូច្នេះ បញ្ជីសំណួរ និងបញ្ជីសរុប បានកសាងឡើង និងដាក់អនុវត្តក្នុងមួយភូមិសំរាប់ឃុំនិមួយៗ ។ សមាជិកក្រុមប្រឹក្សាឃុំអ្នកទទួលបន្ទុក មេភូមិ និង អ្នកធ្វើអង្កេតសំរាប់ភូមិធ្វើសាកមើលមុន បានទទួលការបណ្ដុះបណ្ដាលឱ្យធ្វើអង្កេតជាមួយគ្រួសារទាំងអស់នៅក្នុងភូមិ ។ ការបណ្ដុះបណ្ដាលប្រើពេល ៣ ថ្ងៃ ។ ថ្ងៃទី ១ មានការពិនិត្យពីគោលដៅ និងសំណួរទាំងអស់ក្នុងបញ្ជីសំណួរ ។ ថ្ងៃទី ២ គឺការប្រើបញ្ជីសំណួរសាកមើលនៅក្នុងភូមិ ដោយអ្នកធ្វើសំភាសន៍ម្នាក់ៗ ត្រូវសំភាស ២គ្រួសារ (គ្រួសារតូចមួយ និងគ្រួសារធំមួយ) ដើម្បីមានបទពិសោធន៍ធ្វើការងារជាមួយគ្រួសារទំហំខុសៗគ្នា ។ ថ្ងៃទី ៣ ចំណាយលើការប្រមូលព័ត៌មានត្រឡប់ពីអ្នកធ្វើអង្កេត និងការបំភ្លឺ រឺកែតំរូវសំនួរផ្សេងៗ ដែលមិនច្បាស់ រឺប្រើមិនកើត ។ ការសាកមើលមុននេះ បានជួយកែលំអដល់វិធីបណ្ដុះបណ្ដាល បញ្ជីសំណួរ ការធ្វើសំភាសន៍ និងការវិភាគទិន្នន័យ ។

**ការកសាងឧបករណ៍ចាត់ចែងទិន្នន័យ**

ឧបករណ៍បានកសាងឡើង សំរាប់ទាំងការចាត់ចែងទិន្នន័យដោយដៃ និងដោយប្រើកុំព្យូទ័រ ។ ការចាត់ចែងដោយដៃបានរៀបចំជា ៣ចំណែកគឺ ១) ការបំពេញតារាងដោយអ្នកធ្វើអង្កេត ២) ការសរុបទិន្នន័យដើម្បីកសាងមូលដ្ឋានស្ថិតិមួយសំរាប់ភូមិ និង ៣) ការផ្ទឹមទិន្នន័យតាមភូមិដើម្បីកសាងសៀវភៅស្ថិតិឃុំ ។ សៀវភៅស្ថិតិឃុំនេះ សមាជិកក្រុមប្រឹក្សាឃុំ នឹងយកទៅវិភាគថែមទៀត ដើម្បីកសាងរបាយការណ៍ភាពក្រីក្រក្នុងឃុំដែលជាផលិតផលដ៏ចំបងមួយនៃ CBPMS ។

ជាមួយគ្នានេះ មានការកសាងក្របខ័ណ្ឌបញ្ចូលទិន្នន័យក្នុងកម្មវិធី SPSS សំរាប់ការិយាល័យខេត្តចាត់ចែងទិន្នន័យដោយប្រើកុំព្យូទ័រ ។ វិធីនេះត្រូវបានប្រើប្រាស់ ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការចាត់ចែងទិន្នន័យដោយដៃ ។

### *២.៣ ការជ្រើសរើស និងការបណ្ដុះបណ្ដាលអ្នកធ្វើអង្កេត និងអ្នកចាត់ចែងទិន្នន័យ*

**ការជ្រើសរើសអ្នកធ្វើអង្កេត និងអ្នកចាត់ចែងទិន្នន័យ**

បើសិនធ្វើទៅកើត សមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិ ដែលបានក្លាយជាចំណែកមួយនៃគណៈកម្មាធិការស្ម័គ្រចិត្តខាងផែនការ/ធ្វើថវិការបស់ឃុំ និងអ្នកភូមិដែលមានចំណេះដឹងផ្សេងទៀត នឹងត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាឃុំ រួមជាមួយនឹងក្រុមពិនិត្យតាមដានគំរោង ព្រមទាំងទទួលការបណ្ដុះបណ្ដាលឱ្យក្លាយជាអ្នកធ្វើអង្កេត ។ សំរាប់អ្នកមានជំនាញល្អខាងគិតលេខ គឺមានការបណ្ដុះបណ្ដាលថែម ដើម្បីឱ្យក្លាយជាអ្នកចាត់ចែង ទិន្នន័យ ។ កាលពីដំបូងដៃ ពុំមានការគិតគូរប្រគល់តួនាទីជាដុំកំភួនអ្វីក្នុង អង្កេតទៅឱ្យមេភូមិទេ ។ ប៉ុន្តែ ក្រោយពីបានពិគ្រោះយោបល់ជាមួយក្រុម ប្រឹក្សាឃុំ គេឃើញច្បាស់ថា មេភូមិអាចជួយការងារបានសន្ធឹក និងអាច បំពេញតួនាទីមានប្រយោជន៍ច្រើនជាង ទៅធ្វើជាអ្នកធ្វើសំភាសន៍ ។ មេភូមិជួយនាំផ្លូវអ្នកធ្វើសំភាសន៍ទៅគ្រប់ផ្ទះ ដើម្បីធ្វើជំរឿនគ្រួសារ ។ គេអាចស្នើឱ្យមេភូមិនាំអ្នកធ្វើសំភាសន៍ទៅជួបគ្រួសារចំៗតែម្ដង ហើយបើសិនជាចាំបាច់ អាចជួយណាត់ពេលឱ្យអ្នកធ្វើអង្កេត ។ គាត់ទទួលបានប្រាក់ឧបត្ថម្ភមួយចំនួនតូច ដែលជាចំណែកនៃប្រាក់បំណាច់សំរាប់សមាជិកក្រុមប្រឹក្សាឃុំ ។

**ការបណ្ដុះបណ្ដាលអ្នកធ្វើអង្កេត**

ក្រុមអ្នកពិនិត្យតាមដាន CBPMS បានបណ្ដុះបណ្ដាលអ្នកធ្វើអង្កេតទាំងអស់ ១២២នាក់ ។ មានការចែកបញ្ជីសំណួរដល់អ្នកធ្វើអង្កេតគ្រប់គ្នាមុនពេលបណ្ដុះបណ្ដាល និងការណែនាំឱ្យពួកគេសិក្សាវាជាមុន ។ ក្នុងពេលបណ្ដុះបណ្ដាល អ្នកបណ្ដុះបណ្ដាលបានលើកសំនួរមកពិភាក្សាម្ដងមួយៗ និងពិនិត្យឱ្យជាក់ថា អ្នកធ្វើសំភាសន៍បានយល់ច្បាស់គ្រប់ៗគ្នា ។ វិធីសាស្ត្របណ្ដុះបណ្ដាលដោយមានការចូលរួម បានផ្ដល់ឱកាសឱ្យអ្នកធ្វើអង្កេតគ្រប់គ្នាអាចលើកពីចំណុចព្រួយបារម្ភ និងចែករំលែកបទពិសោធន៍ ជាពិសេសអ្នកដែលបានចូលរួមក្នុងការធ្វើអង្កេតសាកមើលមុន ។ ក្នុងបញ្ជីសំណួរ ចំណែកដែលពិបាកជាងគេ គឺសំណួរស្ដីពីចំណូលចំណាយគ្រួសារ ដែលត្រូវមានការវិភាគកំរិតខ្ពស់ និងការពេញចិត្តផ្ដល់ចម្លើយពីសំណាក់ប្រជាជន ។ នៅក្រចេះ មានការបណ្ដុះបណ្ដាលបន្ថែមមួយថ្ងៃទៀត ដោយសារអ្នកធ្វើអង្កេតមានកំរិតអប់រំទាបបន្តិចនៅខេត្តក្រចេះ និងដើម្បីឱ្យច្បាស់ក្នុងចិត្តថា អ្នកធ្វើសំភាសន៍ទាំងអស់អាចធ្វើការងាររបស់ខ្លួនបានយ៉ាងសក្ដិសិទ្ធិ ។

**ការបណ្ដុះបណ្ដាលអ្នកចាត់ចែងទិន្នន័យ**

នៅខេត្តនិមួយៗ ការបណ្ដុះបណ្ដាលអ្នកចាត់ចែងទិន្នន័យបានធ្វើឡើងជាពីរចំណែក: ការចាត់ចែងទិន្នន័យដោយដៃនៅកំរិតភូមិ និងឃុំ និងការចាត់ចែងទិន្នន័យដោយប្រើកុំព្យូទ័រនៅកំរិតខេត្ត ។

មានអ្នកចូលរួមប្រហែល ៦០នាក់ បានទទួលការបណ្ដុះបណ្ដាលពីការចាត់ចែងទិន្នន័យដោយដៃ គឺប្រហែល ២-៣នាក់ក្នុងមួយភូមិៗ ។ ពួកគេប្រើម៉ាស៊ីនគិតលេខ ដើម្បីបូកសរុប និងគណនាភាគរយ ។ បញ្ហាចោទក្នុងដំណាក់កាលនេះ គឺការល្បើងលេខ ដោយសារកង្វះបទពិសោធន៍ធ្វើការជាមួយតួលេខច្រើនៗ និងធំៗ ជាពិសេសទាក់ទិននឹងដីដាំដុះ ចំណូលចំណាយ និងទ្រព្យសម្បត្តិ ។

ចេញពីបណ្ដាការិយាល័យស្ថិតិខេត្ត បានជ្រើសយកមន្ត្រី ១០នាក់ មកបណ្ដុះបណ្ដាលឱ្យចេះបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។ របៀបប្រើប្រាស់កម្មវិធី SPSS មួយបែបត្រូវបានកសាង និងដាក់បញ្ចូលក្នុងកុំព្យូទ័រឱ្យពួកគេ ។ វាមានប្រយោជន៍ច្រើន ដែលឱ្យមន្ត្រីស្ថិតិបានមកចូលរួមក្នុងការងារនេះ ពីព្រោះ មួយចំនួនធ្លាប់មានពិសោធន៍ហើយក្នុងការបញ្ចូលទិន្នន័យ ប៉ុន្តែគួរឱ្យស្ដាយ ថ្នាក់ខេត្តនៅខ្វះកុំព្យូទ័រដែលមានកំលាំងគ្រប់គ្រាន់ ដែលអាចបញ្ចូលទិន្នន័យ/កម្មវិធី SPSS នេះបាន ។

### *២.៤ ការធ្វើអង្កេត*

មានឧបករណ៍ពីរដែលបានយកមកប្រើប្រាស់ដើម្បីប្រមូលព័ត៌មាន: បញ្ជីសំណួរតាមគ្រួសារ និងបញ្ជីសំនួរសំរាប់ភូមិ និងឃុំ ។ អ្នកធ្វើអង្កេតទាំងអស់

៨៤នាក់បានចុះធ្វើសំភាសន៍ ដោយមានការជួយទ្រទ្រង់ និងពិនិត្យតាមដានដោយផ្ទាល់ពីមេភូមិ ៤៣នាក់ សមាជិកក្រុមប្រឹក្សាឃុំ ២១នាក់ និងដៃគូខាងខេត្ត ២នាក់ ។ អ្នកធ្វើអង្កេតបានធ្វើសំភាសន៍ ១១.៩៣៧គ្រួសារ ។

អ្នកធ្វើអង្កេតទាំងអស់ បានរាយការណ៍ពីការពិបាកយកបានព័ត៌មានពីចំណូលចំណាយគ្រួសារ និងអំពើហិង្សាក្នុងគ្រួសារ ។ អ្នកឆ្លើយសំភាសន៍ភាគច្រើន ព្យាយាមលាក់ចំណូលរបស់ខ្លួន រឺ ក៏មិនអាចរកនឹកឃើញថា ខ្លួនបានចំណូលប៉ុន្មានដែរ ក្នុងមួយខែ រឺមួយឆ្នាំ ។ រឿងនេះ កើតមាននៅក្នុងគ្រប់ភូមិ ហេតុដូច្នេះហើយ ចំណូល និងចំណាយក្នុងគ្រួសារ ជួនកាលមិនស៊ីគ្នាទេ ។

អ្នកធ្វើអង្កេតមួយចំនួន បានលើកពីការពិបាករកជួបមេគ្រួសារដើម្បីធ្វើសំភាសន៍ ពីព្រោះពួកគេទៅធ្វើការឆ្ងាយពីផ្ទះ ។ ម្យ៉ាងទៀតក្នុងភូមិខ្លះ ផ្ទះមួយចំនួននៅឆ្ងាយពីគេ និងមានផ្លូវចេញចូលពិបាក ។

បញ្ជីសំនួរភូមិ និងឃុំ ត្រូវបំពេញដោយមេភូមិ និងមេឃុំ ។ បញ្ជីសំនួរភូមិមានសំនួរស្តីពីភូមិទាំងមូល ។ មេភូមិបំពេញបញ្ជីសំនួរនេះក្រោមការពិនិត្យតាមដានរបស់ក្រុមប្រឹក្សាឃុំ ។ បញ្ជីសំនួរឃុំ ត្រូវបំពេញដោយសមាជិកក្រុមប្រឹក្សាឃុំ ។

អ្នកដៃគូខាងខេត្ត និងសមាជិកក្រុមប្រឹក្សាឃុំ ចូលរួមក្នុងការពិនិត្យតាមដានអ្នកធ្វើអង្កេត ។ សមាជិកក្រុមពិនិត្យតាមដានគំរោង មានភារកិច្ចធ្វើការត្រួតពិនិត្យចោះៗ ដើម្បីធានាគុណភាព និងដំណើររលូនល្អនៃអង្កេត ។

## ២.៥ ការចាត់ចែង និងផ្គុំទិន្នន័យ

បញ្ជីសំនួរទាំង ១១.៩៣៧ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយសមាជិកក្រុមប្រឹក្សាឃុំ ២០នាក់ មកពី ៦ឃុំ ។ មានបញ្ជីសំនួរមិនដល់ ២% ទេដែលមានកំហុសឆ្គង និងទាមទារឱ្យសាមីអ្នកធ្វើអង្កេតទៅធ្វើសំភាសន៍ឡើងវិញលើគ្រួសារជាប់ពាក់ព័ន្ធ ។ កំហុសឆ្គងភាគច្រើនជាប់ទាក់ទងនឹងចំនូលចំនាយគ្រួសារ និងទ្រព្យសម្បត្តិ ។

ក្រោយពីការសំអាតទិន្នន័យ អ្នកធ្វើអង្កេតសំរាប់ភូមិនិមួយៗ ត្រូវធ្វើការបញ្ចូលទិន្នន័យ និងបូកសរុបដោយដៃ ។ ក្នុងឃុំខ្លះដែលអ្នកធ្វើអង្កេតខ្វះខាតជំនាញគិតលេខ សមាជិកក្រុមប្រឹក្សាឃុំត្រូវទទួលបន្ទុកធ្វើការចាត់ចែងទិន្នន័យ ។ សមាជិកក្រុមប្រឹក្សាដែលទទួលបន្ទុកលើគំរោង ក៏ត្រូវត្រួតពិនិត្យ និងបញ្ជាក់យល់ព្រមលើការចាត់ចែងទិន្នន័យដែរ ។

ក្រុមប្រឹក្សាឃុំ ទទួលខុសត្រូវធ្វើការចាត់ចែងទិន្នន័យ បូកសរុប និងតំលើងតារាងស្ថិតិកំរិតឃុំ ដែលអាចយកទៅប្រើប្រាស់ដើម្បីសរសេររបាយការណ៍ស្តីពីភាពក្រីក្ររបស់ឃុំ ។ ក្នុងពេលជាមួយគ្នា ការិយាល័យស្ថិតិតាមខេត្ត ធ្វើការបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ ។

## ២.៦ ការវិភាគ និងការបញ្ជាក់យល់ព្រមលើលទ្ធផលអង្កេត

បញ្ហាចោទធំជាងគេ គឺការកំណត់បន្ទាត់ក្រីក្រសំរាប់ឃុំនីមួយៗ និងភាគរយនៃគ្រួសារក្រីក្រនៅក្នុងភូមិ និងឃុំ ។ រឿងនេះធ្វើឡើងដោយផ្អែកលើចំនាយប្រើប្រាស់ក្នុងមនុស្សម្នាក់ ស្របតាមនិយមន័យថ្នាក់ជាតិ ។ ប៉ុន្តែផ្អែកតាមលទ្ធផលជាដំបូងៗ បន្ទាត់ក្រីក្រត្រឹម ១.២០០រៀល/នាក់/ថ្ងៃ ដែលប្រើប្រាស់ក្នុងរបាយការណ៍ភាពក្រីក្រតាមឃុំរបស់រដ្ឋាភិបាល គឺហាក់ដូចជាទាបពេក ជាពិសេសដោយសារអតិផរណាក្នុងចន្លោះពេលរវាងបច្ចុប្បន្ន និងឆ្នាំ១៩៩៨ ដែលជាឆ្នាំកំណត់បន្ទាត់ភាពក្រីក្រនេះ ។ ក្រោយពីបានពិគ្រោះយោបល់ជាមួយអ្នកធ្វើអង្កេត និងក្រុមប្រឹក្សាឃុំ បន្ទាត់នេះបានតំលើង ដល់ ១.៥០០រៀល (០,៣៨ដុល្លារ) ហើយហេតុផលចំបងគឺ CBPMS មាន

ក្រាហ្វិក ១. ភាគរយនៅក្រោមបន្ទាត់ភាពក្រីក្រក្នុងឃុំចំនួន៣ នៅស្រុកឯកភ្នំ និងឃុំចំនួន៣ នៅស្រុកស្ទួង




គោលដៅសំខាន់ធ្វើការវាស់វែងភាពក្រីក្រពីមួយឆ្នាំទៅមួយឆ្នាំ ។ បើសិនជាបន្ទាត់ក្រីក្របានកែតំរូវតាមអតិផរណា វាអាចវាស់វែងការប្រែប្រួលនៃចំនួនគ្រួសារដែលស្ថិតនៅក្រោមបន្ទាត់ក្រីក្រ ។

## ២.៧ ការផ្សព្វផ្សាយលទ្ធផល

លទ្ធផល CBPMS បានយកទៅផ្សព្វផ្សាយនៅកំរិតជាតិ និងកំរិតមូលដ្ឋាន តាមរយៈសិក្ខាសាលាថ្នាក់ជាតិមួយសំរាប់ដៃគូទាំងអស់ និងស្ថាប័នជាប់ទាក់ទិនរបស់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល, និងតាមរយៈសិក្ខាសាលាពីរសំរាប់ឃុំទាំងអស់ក្នុងស្រុកទាំងពីរ ។ មេឃុំទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសាលា បានបង្ហាញពីការយកចិត្តទុកដាក់ខ្លាំងចង់កសាងរបាយការណ៍តាមដានភាពក្រីក្រក្នុងឃុំរបស់ខ្លួន ហើយពួកគេចាប់ផ្តើមសាកសួរដល់សមាជិកក្រុមប្រឹក្សាឃុំដែលមានបទពិសោធន៍ពី CBPMS សាកល្បង ។ លទ្ធផល CBPMS ក៏គួរបង្ហាញផងដែរ ដល់ស្រុក និងខេត្តឯទៀត បើសិនមានថវិកា ។ ប៉ុន្តែគេរំពឹងថា អាជ្ញាធរខេត្ត នឹងផ្សព្វផ្សាយបទពិសោធន៍នៃគំរោងសាកល្បងនេះ ទៅដល់ឃុំឯទៀតៗតាមរយៈការជួបប្រជុំជាទៀងទាត់របស់ខ្លួន ។

## លទ្ធផលស្តីពីអត្រាភាពក្រីក្រ

ការសិក្សាបានពិនិត្យពីអាំងឌីកាទ័រ CBPMS ផ្សេងៗដែលឆ្លុះបញ្ចាំងទិដ្ឋភាពច្រើនបែបយ៉ាងនៃភាពក្រីក្រ: ប្រជាសាស្ត្រ ការអប់រំ ផ្ទះសំបែង និងដីធ្លី សុខភាព ចំនូលចំនាយ ទ្រព្យសម្បត្តិ អំពើហិង្សា សន្តិសុខ និងសណ្តាប់ធ្នាប់ ។ ប៉ុន្តែក្នុងឯកសារនេះ យើងរាយការណ៍តែពីលទ្ធផលបង្ហាញអត្រាភាពក្រីក្រប៉ុណ្ណោះ ។ យើងគណនាអត្រាភាពក្រីក្រដោយផ្អែកលើចំនាយក្នុងគ្រួសារ ។ បន្ទាត់ភាពក្រីក្រត្រូវកំនត់នៅកំរិត ០,៣៨ដុល្លារ/នាក់ក្នុងមួយថ្ងៃនៅតំបន់ជនបទ ។ ចំនាយក្នុងគ្រួសារ តំណាងឱ្យតំលៃអីវ៉ាន់ដូចតទៅ: អង្ករ អាហារផ្សេងទៀត នំផ្អែមនិងរបស់ប្រហាក់ប្រហែល (មី នំ បង្អែម ភេសជ្ជៈ) ស្រា បារី ការអប់រំ ការថែទាំសុខភាព និងចំនាយផ្សេងទៀត (បុណ្យទាន សំលៀកបំពាក់ សាប៊ូ ទឹក អគ្គិសនី)។ ចំណាយផលិតកម្ម មិនត្រូវបានបូកចូលទេ ។

តទៅទំព័រ ១២

# ពីការកសាងសន្តិភាពទៅសន្តិសុខមនុស្ស?

**លោក ហ៊ាង ផាត និង Larry Strange បានធ្វើការពិចារណាឡើងវិញពីវិធីសាស្ត្រកសាងសន្តិភាព នៅថ្នាក់សហគមន៍ និងការបណ្តុះបណ្តាលជំនាញដោះស្រាយទំនាស់ ។ ***

ថ្វីបើទទួលបានលទ្ធផលល្អច្រើនហើយក្នុងការរក្សាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធក្តី ក៏កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសលូតលាស់តិចជាងគេ (LDC) និងជាប្រទេសទើបបញ្ចប់ទំនាស់ និងពឹងផ្អែកលើជំនួយ ។ កេរ្តិ៍ដំណែលនៃជំលោះប្រដាប់អាវុធយ៉ាងយូរ និងធ្ងន់ធ្ងរ ដែលទើបបញ្ចប់នៅឆ្នាំ១៩៩៨នោះ បានធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងការកសាងរបបប្រជាធិបតេយ្យឱ្យលូតលាស់ពេញវ័យឡើង ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានប្រភពទំនាស់ថ្មីៗ បានផុសឡើងទាក់ទិននឹងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិមនុស្ស វិសមភាពខាងសេដ្ឋកិច្ចនិងសង្គមកិច្ច ទំនាក់ទំនងវប្បធម៌-ជនជាតិ ការពាក់ព័ន្ធក្នុងនយោបាយ លទ្ធភាពមិនស្មើគ្នាក្នុងការទទួលធនធានអភិវឌ្ឍន៍ និងវិវាទការងារ ។ ដោយយ៉ាងហោចណាស់មានប្រជាជនប្រមាណ ៣០% កំពុងរស់នៅក្រោមខ្សែបន្ទាត់ក្រីក្រ ប្រទេសកម្ពុជាកំពុងប្រយុទ្ធតស៊ូដើម្បីដោះស្រាយគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិដ៏ជាក់លាក់ដែលខ្លួនបានទទួលយក ។

*ថ្វីបើទទួលបានលទ្ធផលល្អច្រើនហើយក្នុងការរក្សាសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធក្តី ក៏កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសលូតលាស់តិចជាងគេ និងជាប្រទេសទើបបញ្ចប់ទំនាស់ និងពឹងផ្អែកលើជំនួយ ។*

ក្នុងទសវត្សរ៍កន្លងទៅ មជ្ឈមណ្ឌលដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ (មសអ) នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បានបំពេញតួនាទីយ៉ាង សំខាន់ក្នុងការកសាងសន្តិភាព និងដោះស្រាយទំនាស់ ដោយមានបេសកកម្មកសាងវប្បធម៌សន្តិភាពមួយ និងលើកកំពស់សន្តិសុខមនុស្សនៅកម្ពុជា តាមរយៈការបណ្តុះបណ្តាលការកសាងសន្តិភាព និងការគ្រប់គ្រងទំនាស់ ។ វបសអ ដែលគ្រប់គ្រងលើ មសអ បានធ្វើការស្រាវជ្រាវពីការអភិវឌ្ឍន៍ទាក់ទិននឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងពាណិជ្ជកម្ម, ភាពក្រីក្រ កសិកម្មនិងជីវភាពជនបទ ធនធានធម្មជាតិនិងបរិស្ថាន អភិបាលកិច្ច និងវិមជ្ឈការ ។ អត្ថបទនេះពិនិត្យថា តើសកម្មភាពទាំងពីរអាចបន្សុំចូលគ្នាយ៉ាងដូចម្តេចបាន ដោយផ្តើមចេញពីការកសាងសន្តិភាព និងការបង្ការ/ដោះស្រាយទំនាស់ផ្តោតលើសហគមន៍ឆ្ពោះទៅរកការបណ្តុះបណ្តាលនៅសហគមន៍ ដែលត្រូវបានរៀបចំក្នុងគោលគំនិតបង្កើនសន្តិសុខមនុស្ស និងដែលកំណត់នូវមូលហេតុនៃទំនាស់ និងលទ្ធភាពបង្ការ គ្រប់គ្រង និងដោះស្រាយទំនាស់នៅក្នុងគំរូអភិវឌ្ឍន៍នោះ ។ នេះមានន័យថា ត្រូវរៀបចំការបណ្តុះបណ្តាលនៅសហគមន៍ ឱ្យមានលក្ខណៈផ្សារភ្ជាប់យ៉ាងរឹងមាំ ទៅនឹងគំរូវការអភិវឌ្ឍន៍ដ៏ជាក់លាក់ និងបញ្ហាចោទរបស់សហគមន៍នៅមូលដ្ឋាន ដោយផ្អែកលើការវាយតំលៃពីសន្តិសុខមនុស្ស និងករណីសិក្សាខាងអភិវឌ្ឍន៍ ទទួលបានការស្រាវជ្រាវពីបញ្ហាចោទជាច្រើន ។

## ឧទាហរណ៍បញ្ជាក់មួយៈ បទពិសោធន៍ថ្មីៗរបស់ មសអ នៅស្រុកវាលវែង

ស្រុកវាលវែងស្ថិតក្នុងខេត្តពោធិសាត់ និងជាស្រុកមួយដ៏ក្រីក្រ នៅឆ្ងាយដាច់ស្រយាលក្នុងជួរភ្នំក្រវាញ ជិតព្រំដែនកម្ពុជា-ថៃ ។ ផ្ទៃដីប្រហែល ២៥% ក្នុងស្រុកនេះ គឺជាតំបន់ព្រៃការពារ ។ ពីទីក្រុងពោធិសាត់ទៅទីរួមស្រុកសព្វថ្ងៃ មានផ្លូវថ្នល់ល្អ ប៉ុន្តែក្នុងចំណោម ៥ឃុំនៃស្រុកនេះ មាន២ឃុំគឺអាចទៅមកបានតែតាមម៉ូតូ នៅរដូវប្រាំងប៉ុណ្ណោះ ។ ដោយសារស្រុកនេះជាមូលដ្ឋានយូរជាងគេ និងស្ថិតក្រោយគេ នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ប្រជាជនភាគច្រើន គឺជាអតីតខ្មែរក្រហមដែលនៅដាច់ឆ្ងាយ ទាំងខាងរូបកាយ សង្គម និងចិត្តសាស្ត្រ ពីតំបន់ឯទៀតនៃប្រទេសកម្ពុជា ។

របរចិញ្ចឹមជីវិតចំបងនៅវាលវែង គឺធ្វើចំការ (ដាំស្រូវ និងដំណាំផ្សេងទៀតដូចជា ពោត សណ្តែក សណ្តែកដី ល្ង ដំឡូង) និងពឹងលើព្រៃឈើក្នុងស្រុក ក្នុងការបរបាញ់ រកអុស ជ័រ ផ្តៅ បន្លែ ផ្លែឈើ និងមើមឈើ ។ ថ្វីបើ ស្រុកនេះអំនោយផលដល់ការដាំដុះ ប៉ុន្តែ ផលិតកម្មជួបឧបសគ្គច្រើនណាស់ ដោយកង្វះឧបករណ៍ គោក្របី និងផ្លូវថ្នល់ដែលអាចប្រើបានគ្រប់រដូវ សំរាប់ដឹកផលិតផលចំការទៅទីផ្សារ ។ ដីដាំដំណាំ ក៏មានកំរិត ដោយសារត្រូវរក្សាទុកព្រៃការពារ ហើយលទ្ធភាពប្រមូលយកផលិតផលព្រៃឈើ ដើម្បីបំពេញបន្ថែមលើចំណូលពីការធ្វើកសិកម្ម ក៏មានកំហិតដែរ ដោយសារសកម្មភាពស្ថាប័នអភិរក្សព្រៃឈើ គ្រាប់មីន និងខ្វះហេដ្ឋារចនាសម្ព័ន្ធ ។ ប្លែកពីតំបន់ឯទៀតក្នុងប្រទេសកម្ពុជា នៅវាលវែងមានតែអង្គការសង្គមស៊ីវិលមួយចំនួនតូចប៉ុណ្ណោះ ដែលបានមកធ្វើការងារអភិវឌ្ឍន៍សហគមន៍ ។

ជាប្រពៃណី សហគមន៍ក្នុងមូលដ្ឋានតែងពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានធម្មជាតិដើម្បីចិញ្ចឹមជីវិត ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗ ប្រជាជននៅវាលវែងមួយចំនួនត្រូវបានចាប់ខ្លួន ផាកពិន័យ និងរឹបអូសសំភារៈ ដោយសារបានចូលព្រៃការពារ ដើម្បីប្រមែប្រមូលផលិតផលព្រៃឈើ ។ តាមរបៀបរបបដ៏ប្លែកមួយ អង្គការអភិរក្សអន្តរជាតិចំនួន ២ បានទទួលអាណត្តិពីរដ្ឋាភិបាល ឱ្យត្រួតមើលតំបន់ការពារ និងមានសិទ្ធិអំណាចអនុវត្តវិធានការដាក់ទោសទណ្ឌ ដែលជារឿយៗគឺបានអនុវត្តដោយឯករាជ្យដាច់ពីអាជ្ញាធរមូលដ្ឋាន ។ អ្នកដឹកនាំសហគមន៍មូលដ្ឋាន នាពេលចូលរួមក្នុងវគ្គបណ្តុះបណ្តាលពីការកសាងសន្តិភាពរបស់ វបសអ បានសំគាល់ថា រឿងនេះគឺជាប្រភពចំបងមួយនៃទំនាស់ដោយថាហេតុដ៏ធ្ងន់ធ្ងរនៅស្រុកវាលវែង ។ ការហាមឃាត់ដល់លទ្ធភាពរបស់ប្រជាជនក្នុងការប្រើប្រាស់ផលិតផលព្រៃឈើបានបង្ក និងអូសបន្លាយការតានតឹង និងការប្រឈមមុខគ្នា រវាងសហគមន៍ និងអង្គការអភិរក្សដែលរដ្ឋាភិបាលបានផ្តល់អាណត្តិ ហើយជារឿយៗ

* អត្ថបទនេះ ផ្អែកលើឯកសារមួយដែលយកទៅបង្ហាញក្នុងសន្និសីទស្តីពីយុត្តិធម៌ សន្តិភាព និងការផ្សះផ្សានៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក រៀបចំដោយមជ្ឈមណ្ឌលសំរាប់ការសិក្សាពីសន្តិភាព និងទំនាស់នៃសាកលវិទ្យាល័យ Queensland នៅឯទីក្រុង Brisbane នៅថ្ងៃទី ១-៣ មេសា ២០០៥ ។ ឯកសារនេះបានសរសេរឡើងដោយមានការជួយមតិ និងព័ត៌មានពីក្រុមបណ្តុះបណ្តាល មសអ (ហ៊ុយ រំដួល, ទូច វ៉ារីន, មាស សាវ៉ាត, ដួង វិរតន៍) ។

មន្ត្រីខេត្ត និងស្រុក ត្រូវបំពេញតួនាទីដ៏លំបាក ជាអ្នកនៅកណ្ដាល ។

## ការបណ្ដុះបណ្ដាលពីការកសាងសន្តិភាព និងការដោះស្រាយទំនាស់

វាលវែង គ្រាន់តែជាឧទាហរណ៍មួយនៃទំនាស់ជាច្រើនដែលកើតមាននៅកម្ពុជាអំពីការបែងចែកធនធានធម្មជាតិមិនស្មើភាពគ្នា សិទ្ធិមិនគ្រប់គ្រាន់របស់សហគមន៍ និងបុគ្គល ក្នុងការទទួលបានសន្តិសុខ និងការអភិវឌ្ឍន៍ ។ សព្វថ្ងៃមានការគំរាមកំហែងពិតៗនៃទំនាស់អំពីកម្មសិទ្ធិដី លទ្ធភាពប្រើប្រាស់ដីកសិកម្មនិងព្រៃឈើ សម្បទានដី និងធនធានធម្មជាតិ ដែលអាចនាំទៅដល់ការបាត់បង់ជីវិត ការរងរបួសធ្ងន់ធ្ងរ ការជំលៀសប្រជាជន និងការបំផ្លិចបំផ្លាញផ្ទះសំបែងនិងជីវភាពរស់នៅ ។ ឧទាហរណ៍ នៅថ្ងៃ ២៥ មីនា ២០០៥ មានស្លាប់ប្រជាជន ៥នាក់ និងរបួសធ្ងន់ ៣នាក់ នៅប៉ោយប៉ែត នៅពេលកងរាជអាវុធហត្ថ និងប៉ូលីស បានបាញ់ទៅលើអ្នកភូមិរាប់រយនាក់ដែលកំពុងតវ៉ា ប្រឆាំងនឹងការប្រើកំលាំងបណ្ដេញពួកខ្លួនចេញពីដីវិវាទមួយកន្លែង ។ ការអនុវត្តន៍សាលក្រមតុលាការដែលទាក់ទិននឹងវិវាទដីធ្លីមួយនេះ រវាងមេភូមិ និងប្រជាជនក្រីក្រជាង ២០០គ្រួសារ ក៏បានក្លាយទៅជាសោកនាដកម្ម ហើយករណីនេះគ្រាន់តែព្រឹត្តិការណ៍ថ្មីជាងគេក្នុងរឿងរ៉ាវបន្តគ្នារដឹកនៃការប្រឈមមុខគ្នាដ៏តឹងតែងដែលជារឿយៗ មានទាំងហិង្សាផងរវាងសហគមន៍មូលដ្ឋាន ហើយនិងអាជ្ញាធរ អំពីដីនិងព្រៃសម្បទាន ការបណ្ដេញចេញពីដី និងការទន្ទ្រានយកធនធានធម្មជាតិដោយអ្នកមានឋានៈខ្ពស់ ។ ទំនាស់បែបនេះមានលទ្ធភាពពិតៗ នឹងបង្កការរីករាលដ៏ធ្ងន់ធ្ងរនៅជនបទ និងតំបន់ដាច់ស្រយាល ។ ហើយនេះជាបញ្ហាប្រឈមដ៏ចំបងមួយ សំរាប់រដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពនិងសុវត្ថិភាព និងដោះស្រាយមូលហេតុនៃបណ្ដឹងតវ៉ាទាំងនេះ ។

> *ទំនាស់បែបនេះមានលទ្ធភាពពិតៗ នឹងបង្កការរីករាលដ៏ធ្ងន់ធ្ងរនៅជនបទ និងតំបន់ដាច់ស្រយាល ។ ហើយនេះជាបញ្ហាប្រឈមដ៏ចំបងមួយសំរាប់រដ្ឋាភិបាលក្នុងការរក្សាស្ថិរភាពនិងសុវត្ថិភាព និងដោះស្រាយមូលហេតុនៃបណ្ដឹងតវ៉ាទាំងនេះ ។*

នៅក្នុងបរិបទនេះហើយដែល មសអ ដំណើរការវគ្គបណ្ដុះបណ្ដាលខាងកសាងសន្តិភាព និងដោះស្រាយទំនាស់នៅកន្លែងដាច់ស្រយាលនានា[1] ក្នុងអតីតតំបន់មូលដ្ឋានខ្មែរក្រហម រឺតំបន់ផ្សះផ្សា ដែលតំបន់ខ្លះទើបផ្សះផ្សាជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ ថ្មីៗនេះ ។ ការបណ្ដុះបណ្ដាលនៅតំបន់ទាំងនោះ បានផ្ដោតលើសមាជិកក្រុមប្រឹក្សាឃុំ មន្ត្រីស្រុក បុគ្គលិក NGO ក្នុងស្រុក សមាគមតាមវត្ត និងសមាគមនារី មេភូមិ មេប៉ូលីស អាវុធហត្ថ និងកងទ័ពនៅមូលដ្ឋាន ដែលអាចមានតួនាទីក្នុងការដោះស្រាយទំនាស់នៅតាមអង្គភាពរៀងៗខ្លួន ។ ការបណ្ដុះបណ្ដាលផ្ដល់ជំនាញ និងវិធីសាស្ត្រដែលអាចយកទៅប្រើប្រាស់នៅក្នុងស្ថានភាពមានទំនាស់ ប៉ុន្តែមិនធំធេងរហូតដល់ព្យាយាមដោះស្រាយដល់ឫសគល់ទំនាស់នោះទេ ។ សិក្ខាកាមត្រូវបានជ្រើសរើសយ៉ាងប្រយ័ត្នប្រយែង ដោយមានការយកចិត្តទុកដាក់ពិសេសដល់អ្នកដែលមានស្ថានភាព អាចយកចំណេះដឹងទៅអនុវត្តក្នុងជីវភាពសហគមន៍បាន ជាអាទិ៍ មន្ត្រីរាជការក្នុងមូលដ្ឋាន (មានទាំងប៉ូលីស ទាហានផង), បុគ្គលិក NGOs, អ្នកដឹកនាំសហគមន៍, សមាជិកក្រុមប្រឹក្សាឃុំ, អ្នកធ្វើការងារ និងសកម្មជនខាងសន្តិភាព, និងព្រះសង្ឃ ។

តើយើងដឹងអ្វីខ្លះពីប្រសិទ្ធិភាព និងឥទ្ធិពលនៃការបណ្ដុះបណ្ដាល ហើយតើមានអ្វីខ្លះដែលយើងមិនទាន់ដឹង? តាមបទពិសោធន៍នៅវាលវែង យើងបានដឹងតាមព័ត៌មានត្រឡប់ពីអ្នកចូលរួម និងការវាយតំលៃលើវគ្គសិក្សាថាការបណ្ដុះបណ្ដាលត្រូវបានវាយតំលៃយ៉ាងខ្ពស់ថាជាការកសាងសមត្ថភាពសហគមន៍មួយដែលបានផ្ដល់ការយល់ដឹង និងជំនាញ ។ ដោយបានប្រមូលអ្នកដឹកនាំសហគមន៍ ឱ្យមកធ្វើការរួមគ្នាជាមួយអង្គការខាងក្រៅ និងអព្យាក្រឹតមួយដែលគេទុកចិត្ត វគ្គទាំងនេះក៏បានដើរតួជាកាតាលីករនៃការកសាងសហគមន៍ផងដែរ ។ យើងបានដឹងពីករណីជាច្រើនដែលក្នុងនោះជំនាញទទួលបានពីការបណ្ដុះបណ្ដាល គឺមានប្រយោជន៍ជាក់ស្ដែងក្នុងការជួយដល់តួអង្គនានាក្នុងសហគមន៍ ឱ្យចេះផ្ដល់មតិណែនាំពីការប្រយ័ត្នប្រយែង និងបង្កើតភាពស្ងប់ល្អនៅក្នុងស្ថានការណ៍តឹងតែងផ្សេងៗក្នុងសហគមន៍ រឺក៏គិតគូរឡើងវិញឱ្យល្អិតល្អន់មុននឹងប្រើប្រាស់មធ្យោបាយទំនាស់ ។ យើងដឹងថា ការបណ្ដុះបណ្ដាលក្នុងតំបន់ផ្សះផ្សាមានតួនាទីវិជ្ជមានក្នុងការលើកកំពស់ការយល់ដឹង និងការទទួលរាប់អានគ្នាទៅវិញទៅមករវាងអតីតខ្មែរក្រហម និងអ្នកមិនដែលនៅក្នុងជួរខ្មែរក្រហម ដែលរស់នៅជិតខាងគ្នា និងមានការទាក់ទងគ្នាប្រចាំថ្ងៃ ។ យើងដឹងទៀតថា មន្ត្រីរាជការទាំងនៅខេត្តពោធិសាត់ និងស្រុកវាលវែង បានយល់ឃើញថា ការបណ្ដុះបណ្ដាលមានប្រយោជន៍ច្រើនដល់សហគមន៍ ពីព្រោះគេបានឆ្លើយសំភាសន៍បញ្ជាក់រឿងនេះ និងបានលើកសំណើជាច្រើនដង សុំឱ្យមានកម្មវិធីបណ្ដុះបណ្ដាលច្រើនថែមទៀតដែលមានគោលដៅដូចគ្នា ប៉ុន្តែស៊ីជំរៅជាងមុន ។ ប៉ុន្តែរឿងដែលយើងមិនទាន់ដឹង ក៏សំខាន់ណាស់ដែរគឺថា តើការបណ្ដុះបណ្ដាលមានឥទ្ធិពលអ្វីខ្លះក្នុងការដោះស្រាយឫសគល់នៃទំនាស់ រឺក៏ជួយឱ្យសហគមន៍ចាត់ចែងបានកាន់តែប្រសើរ រឺសំរបតាមបញ្ហាប្រឈមនានានៃការអភិវឌ្ឍន៍ ដែលជារឿយៗតែងបង្កឱ្យមានទំនាស់នោះ ។

## ពីការកសាងសន្តិភាពទៅ សន្តិសុខមនុស្ស?

ឧទាហរណ៍នៃការបណ្ដុះបណ្ដាលនៅវាលវែងបង្ហាញថា ថ្វីបើសព្វថ្ងៃសហគមន៍ខ្លះមានចំណេះដឹង ជំនាញ និងសមត្ថភាព ដើម្បីបង្អាក់ និងទប់ស្កាត់សកម្មភាពហិង្សាក្ដី ក៏គេមិនទាន់អាចដោះស្រាយដល់ឫសគល់ទំនាស់ទេ ជាពិសេសក្នុងរឿងអសន្តិសុខស្បៀង ជីវភាពរស់នៅ និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ពីព្រោះវាចាក់ឫសចូលទៅក្នុងបញ្ហាប្រឈមខាងអភិវឌ្ឍន៍ដែលជ្រាលជ្រៅខ្លាំង និងដែលតួអង្គនានាក្នុងសហគមន៍មិនទាន់គ្រប់គ្រងបាននៅឡើយទេ ។ នេះជាចំណុចដែលគោលគំនិតនៃសន្តិសុខមនុស្សនៅក្នុងបរិបទនៃការអភិវឌ្ឍន៍ អាចមានប្រយោជន៍សំរាប់ប្រទេសកម្ពុជា និងសំរាប់ការរៀបចំករណីសិក្សា និងកម្មវិធីបណ្ដុះបណ្ដាលសហគមន៍ដែលផ្អែកលើការស្រាវជ្រាវនានា ។

របៀបវារៈរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៩២ សំរាប់សន្តិភាព បានកំណត់និយមន័យ ការកសាងសន្តិភាពថាជាបណ្ដាសកម្មភាពសំរាប់សំគាល់ឱ្យឃើញ និងទ្រទ្រង់ដល់រចនាសម្ព័ន្ធនានាដែលជួយពង្រឹងសន្តិភាព ដើម្បីជៀសវាងការធ្លាក់ចូលសាថ្មីទៅក្នុងទំនាស់ ។ ក្នុងនិយមន័យនេះ គឺមានទាំងការទប់ស្កាត់ការកើតមានទំនាស់ឡើងវិញ, ការកសាងរចនាសម្ព័ន្ធផ្សេងៗដែលអាចជួយពង្រឹងសន្តិភាព និងលើកកំពស់អារម្មណ៍មានទំនុកចិត្ត និងសុភមង្គល, ការបំបាត់បញ្ហាបង្កប់ខាងសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌ និងមនុស្សធម៌, ព្រមទាំងការបម្លែងរចនាសម្ព័ន្ធជាតិ និងសមត្ថភាពនានាដែលនៅទន់ខ្សោយ ។ តាមធម្មតា ការកសាងសន្តិភាព រួមមាន បណ្ដាសកម្មភាពដូចជា ការកាត់បន្ថយសព្វាវុធ, ការបញ្ឈប់ចលនាកងទ័ព និងការរំសាយ

កងទ័ព, ការប្រមូល និងបំផ្លាញអាវុធចោល, ការតាមដានការបោះឆ្នោត, ការដាក់ពង្រាយប៉ូលីសស៊ីវិល, ការធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន, និងការរៀបចំសណ្ដាប់ធ្នាប់ឡើងវិញ, កិច្ចការពារសិទ្ធិមនុស្ស, កំណែទម្រង់ រឺការពង្រឹងស្ថាប័នរដ្ឋាភិបាល, ការលើកកំពស់ការចូលរួមខាងនយោបាយជាផ្លូវការ និងក្រៅផ្លូវការ, និងការបង្កើតរចនាសម្ព័ន្ធនានាសំរាប់ធ្វើឱ្យសន្តិភាពក្លាយជាក្រឹត្យក្រម ។ រឿងទាំងនេះ កម្ពុជាបានជួបប្រទះទាំងអស់នៅក្នុងការងារកសាងឡើងវិញនិងការអភិវឌ្ឍន៍ នៅក្នុងដំណើរឆ្លងកាត់ពីរយៈពេលមានទំនាស់ មកដល់រយៈពេលក្រោយទំនាស់ ។

និយមន័យសន្តិសុខមនុស្សនៅឆ្នាំ២០០៣ របស់គណៈកម្មការសន្តិសុខមនុស្សគឺៈ

*"ដើម្បីការពារកក្តាស្នូលនៃជីវិតរបស់មនុស្សគ្រប់គ្នាតាមបែបបទមួយ ដែលលើកកំពស់សេរីភាពរបស់មនុស្ស និងការសំរេចគោលដៅរបស់មនុស្ស... ។ វាមានន័យថា ជាកិច្ចការពារមនុស្សជាតិពីស្ថានការណ៍ និងការគំរាមកំហែងធ្ងន់ធ្ងរនៅគ្រប់ទិសទី ។ វាជាការប្រើប្រាស់ដំណើរការនានាដែលឈរលើកំលាំង និងបំណងប្រាថ្នារបស់ប្រជាជន ។ វាក៏ជាការបង្កើតប្រព័ន្ធខាងនយោបាយសង្គមកិច្ច សេដ្ឋកិច្ច យោធា និងវប្បធម៌ ដែលគួបផ្សំគ្នា ជួយផ្ដល់ឱ្យមនុស្សជាតិនូវមូលដ្ឋានគ្រឹះសំរាប់ការរួចរស់ជីវិត ការរកចិញ្ចឹមជីវិត និងភាពថ្លៃថ្នូរ"* [2] ។

សន្តិសុខមនុស្សពាក់ព័ន្ធនឹងសន្តិសុខរបស់បុគ្គលម្នាក់ៗ និងសហគមន៍របស់ពួកគេ មិនមែនពាក់ព័ន្ធនឹងរដ្ឋ និងប្រជាជនទាំងមូលទេ ។ វាមានទិដ្ឋភាព ៧យ៉ាងគឺ សន្តិសុខខាងសេដ្ឋកិច្ច សន្តិសុខស្បៀង សន្តិសុខខាងសុខភាព សន្តិសុខខាងបរិស្ថាន សន្តិសុខផ្ទាល់ខ្លួន សន្តិសុខសហគមន៍ និងសន្តិសុខនយោបាយ ។

សន្តិសុខមនុស្សមានលក្ខណៈផ្ដោតលើមនុស្ស និងបើកចំហសំរាប់គ្រប់គ្នា គឺមិនមែនមានលក្ខណៈទប់ទល់ទេ ។ វាខុសប្លែកពីការកសាងសន្តិភាពត្រង់ថា វាដោះស្រាយទាំងទំនាស់ និងបញ្ហាអភិវឌ្ឍន៍ ក្នុងនេះមានទាំងការ ជម្លៀសការរើសអើង និងការធ្វើទុក្ខបុកម្នេញលើសហគមន៍ងាយរងគ្រោះ ព្រមទាំងអសន្តិសុខផ្សេងៗទាក់ទិននឹងភាពក្រីក្រ សុខភាព ការអប់រំ ការមិនស្មើភាពខាងយេនឌ័រ ហើយវាក៏ព្យាយាមដោះស្រាយវិសមភាពប្រភេទឯទៀតតាមរយៈការធានាសុវត្ថិភាពឱ្យបានរួចផុតពីការគំរាមកំហែងរ៉ាំរ៉ៃ ដូចជាការអត់ឃ្លាន ជំងឺតម្កាត់ និងការគៀបសង្កត់, ព្រមទាំងកិច្ចការពារមនុស្សទល់នឹងការរអាក់រអួលភ្លាមៗនៅក្នុងជីវិតប្រចាំថ្ងៃ ទាំងនៅផ្ទះ នៅក្នុងការងារ រឺនៅក្នុងសហគមន៍ ។

## ការវាយតំលៃពីសន្តិសុខមនុស្ស និងការបណ្ដុះបណ្ដាលគឺជាវិធីសាស្ត្រមានប្រយោជន៍?

មជ្ឈមណ្ឌលសហប្រជាជាតិសំរាប់ការអភិវឌ្ឍន៍តាមតំបន់ (United Nations Centre for Regional Development: UNCRD) បានសំគាល់សន្តិសុខមនុស្សថាជាការលុបបំបាត់ រឺការកាត់បន្ថយភាពងាយរងគ្រោះចំពោះគ្រោះថ្នាក់ខាងសេដ្ឋកិច្ច បរិស្ថាន សង្គមកិច្ច និងវប្បធម៌ ដែលធ្វើឱ្យខូចខាតដល់ការអភិវឌ្ឍន៍មានចីរភាព ។ UNCRDក្នុងពេលថ្មីៗ បានធ្វើការវាយតំលៃពីសន្តិសុខមនុស្សនៅប្រទេសឡាវ ដោយប្រើការវិភាគពីភាពងាយរងគ្រោះ និងយុទ្ធសាស្ត្រដោះស្រាយរបស់សហគមន៍ ព្រមទាំងការវាយតំលៃពីសមត្ថភាពនៅកំរិតភូមិ និងស្រុក និងដោយផ្ដោតលើបញ្ហាមួយចំនួន ដូចជាចំណាប់អារម្មណ៍របស់គ្រួសារនានាអំពីហានិភ័យ និងយុទ្ធសាស្ត្រដោះស្រាយ, លទ្ធភាពទទួលបានឥណទាន សុខភាព ការបារម្ភរបស់នារី និងការធ្វើផែនការវិមជ្ឈការ ។ សំរាប់ វិបសអ និង មសអ ការវាយតំលៃពីសន្តិសុខមនុស្ស និងវិធីសាស្ត្របណ្ដុះបណ្ដាលនេះ បានបំផុសសំនួរសំខាន់ៗមួយចំនួនស្ដីពីចំណងទាក់ទងជាយថាហេតុ រវាងការស្រាវជ្រាវខាងអភិវឌ្ឍន៍ទាក់ទិននឹងគោលនយោបាយ ហើយនិងការងារខាងគោលនយោបាយ, និងរវាងការកសាងសន្តិភាពសហគមន៍ និងការបណ្ដុះបណ្ដាលពីការបម្លែងទំនាស់ ។

តើសន្តិសុខមនុស្សជាគោលគំនិតមានប្រយោជន៍ និងសមស្របនឹងកម្ពុជា រឺទេ និងតើយើងត្រូវកសាង និងបញ្ជាក់គាំទ្ររឿងនេះយ៉ាងណា? រឺក៏តើមានគ្រោះអ្វីរឺទេ បើគ្រាន់តែ "នាំចូល" គោលគំនិតពីការអភិវឌ្ឍន៍របស់អន្តរជាតិមួយមកទៀត ដែលនឹងពង្វាងកាន់តែខ្លាំងថែមទៀតនូវការយកចិត្តទុកដាក់ និងសមត្ថភាពសំរាប់ជំរុញឱ្យមានការលូតលាស់នៅក្នុងការអភិវឌ្ឍន៍សំខាន់ៗបំផុត? ប្រសិនបើវាជាគោលគំនិតមានប្រយោជន៍ តើយើងអាចធានាយ៉ាងណាឱ្យវាមានលក្ខណៈ "កម្ពុជា" ដោយមានភាពជាម្ចាស់ និងការចូលរួមរបស់ជនកម្ពុជានៅគ្រប់កំរិតនៃរដ្ឋាភិបាលនៅក្នុងសង្គមស៊ីវិល និងនៅក្នុងសហគមន៍មូលដ្ឋាន? ហើយតើរឿងនេះមានពាក់ព័ន្ធអ្វីខ្លះដល់ការអភិវឌ្ឍន៍រយៈពេលវែងនូវសមត្ថភាពរបស់ជនកម្ពុជា ក្នុងការប្រើប្រាស់គោលគំនិតខាងលើឱ្យមានប្រសិទ្ធិភាពក្នុងការតាក់តែង និងការអនុវត្តន៍កម្មវិធី? តើយើងតាក់តែងឧបករណ៍យ៉ាងណាឱ្យបានកាន់តែមានប្រសិទ្ធិភាព និងមានការចូលរួមកាន់តែច្រើន សំរាប់វាយតំលៃពីតំរូវការខាងសន្តិសុខមនុស្សរបស់សហគមន៍ (ជាពិសេសសំរាប់ការគំរាមកំហែងធំៗ) ហើយឈរលើមូលដ្ឋាននេះ គេក៏អាចរៀបចំ និងវាយតំលៃពីការអភិវឌ្ឍន៍សមត្ថភាព និងកម្មវិធីបណ្ដុះបណ្ដាលអំពីសន្តិសុខមនុស្ស សំរាប់ប្រើប្រាស់នៅគ្រប់កំរិតផងដែរ ។

នៅដំណាក់កាលដំបូងនេះ យើងជឿថា សន្តិសុខមនុស្សអាចក្លាយជាគោលគំនិត និងជាវិធីសាស្ត្រដ៏មានប្រយោជន៍ ប៉ុន្តែត្រូវមានការស្រាវជ្រាវថែមទៀត ។ ប្រទេសកម្ពុជា នៅតែត្រូវការឱ្យមានការបណ្ដុះបណ្ដាលតាមសហគមន៍ដ៏ជាក់លាក់ ស្ដីពីការកសាងសន្តិភាព និងការទប់ស្កាត់ គ្រប់គ្រង និងដោះស្រាយទំនាស់ និងវិធីសាស្ត្រផ្សះផ្សាតាមរូបភាពកសាងសហគមន៍ ជាពិសេសទាក់ទិននឹងបញ្ហាមិនទាន់ដោះស្រាយផ្សេងៗជុំវិញរឿងរបបខ្មែរក្រហម ហើយនិងការប្រមើលឃើញពីផលប៉ះពាល់នៃតុលាការកាត់ទោសខ្មែរក្រហម ។ ប៉ុន្តែទៅអនាគត អាចថា ការបណ្ដុះបណ្ដាលផ្អែកលើសហគមន៍បែបនេះអាចកាន់តែមានប្រសិទ្ធិភាពថែមទៀត បើសិនជាគេតាក់តែងនិងដំណើរការវានៅក្នុងបរិបទសន្តិសុខមនុស្ស ដែលផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពសំខាន់ៗនៃតំរូវការខាងសង្គមកិច្ច នយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងរបស់សហគមន៍មូលដ្ឋានដ៏ជាក់លាក់នានា ។ រឿងនេះអាចមានផលប៉ះពាល់យ៉ាងធំចំពោះការងារ វិបសអ និងចំពោះការអភិវឌ្ឍន៍សហគមន៍នៅកម្ពុជា ។

### កំណត់សំគាល់

១ មសអ បានបណ្ដុះបណ្ដាលស្ដីពីធ្វើការរួមគ្នាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ៣វគ្គ នៅស្រុករំាលវែង ខេត្តពោធិសាត់ ២វគ្គនៅស្រីស្នំ ខេត្តសៀមរាប ៤វគ្គ នៅត្រពាំងប្រាសាទ និងអន្លង់វែង ខេត្តឧត្ដរមានជ័យ, ២វគ្គ នៅសំឡូត ខេត្តបាត់ដំបង និង ២ វគ្គ នៅភ្នំវល្លិ៍ ខេត្តកំពត ។

២. Human Security Now: Fianal Report of the Commission on Human Security 2003, p.4.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

កំណើនសេដ្ឋកិច្ចសាកលបានថយចុះនៅត្រីមាសទី៤ ២០០៤ បើធៀបនឹងត្រីមាសមុន ដោយសារជាសំខាន់ ការថយកំណើនក្នុងសេដ្ឋកិច្ចធំបងៗ ដូចជា សហរដ្ឋអាមេរិក (US) តំបន់អឺរ៉ូ ជប៉ុន និងប្រទេសមួយចំនួនទៀតនៅអាស៊ីខាងកើត ។ ប៉ុន្តែកំណើនសំរាប់ពេញមួយឆ្នាំ មានកំរិត ៥% ដែលជាតួលេខខ្ពស់បំផុតក្នុងរយៈ ២០ឆ្នាំ ។

ផសស ពិត របស់ US មានអត្រាកំណើនប្រចាំឆ្នាំ ៣,៨%នៅត្រីមាសទី៤ ២០០៤ ដោយធ្លាក់ចុះពី ៣,៩% នៅត្រីមាសទី៣ ។ រឿងនេះឆ្លុះបញ្ចាំងជាសំខាន់ ការស្ទុះកំណើនក្នុងការនាំចូលទំនិញនិងសេវា ហើយនិងការថយកំណើនក្នុងចំនាយប្រើប្រាស់ផ្ទាល់ខ្លួន (personal consumption expenditure: PCE) សំរាប់ទំនិញជាប់លាប់ និងក្នុងការនាំចេញទំនិញនិងសេវា ។ យោងតាមការិយាល័យវិភាគសេដ្ឋកិច្ច PCE ពិត កើន ៤,២% នៅត្រីមាសទី៤ ធៀបនឹង ៥,១% នៅត្រីមាសទី៣ ។ ការនាំចេញពិតនូវទំនិញនិងសេវាកើន ៣,២% នៅត្រីមាសទី៤ ធៀបនឹងកំណើន ៦,០% នៅត្រីមាសទី៣ ។

ផសស ពិត នៅតំបន់អឺរ៉ូ នៅត្រីមាសទី៤ កើនតាមអត្រាប្រចាំឆ្នាំ ១,៦% និងកើន ០,២% បើធៀបនឹងត្រីមាសមុន ។ កំណើនដ៏ខ្សោយនេះគឺដោយសារកំណើនយឺតៗក្នុងចំណាយប្រើប្រាស់ចុងក្រោយតាមគ្រួសារ ការវិនិយោគ និងការនាំចេញ ដែលបានត្រឹម ០,៥%, ០,៦%, និង ០,៥% រៀងៗគ្នា ។

នៅត្រីមាសទី៤ ផសស ពិត នៅជប៉ុន កើន ០,៨% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប៉ុន្តែវាមានអត្រាកំណើនប្រចាំឆ្នាំថយចុះ ០,៥% បើធៀបនឹងត្រីមាសមុន ។ ការថយចុះនេះ មួយភាគធំបណ្តាលពីការថយចុះក្នុងចំណាយប្រើប្រាស់ពិតតាមអត្រាប្រចាំឆ្នាំ ១,៣% ធៀបនឹង ០,៨% នៅត្រីមាសទី៣ ២០០៤ ។ ម្យ៉ាងទៀត ការនាំចូលដែលកើនលឿនជាងការនាំចេញ ក៏មានឥទ្ធិពលសង្កត់ចុះនូវកំណើន ផសស ពិតផងដែរ ។

ផសស ចិននៅត្រីមាសទី៤ ២០០៤ មានកំណើនខ្លាំងតាមអត្រាប្រចាំឆ្នាំ ៩,៥% ។ លទ្ធផលដ៏ខ្ពស់ឥតរំពឹងទុកនេះ គឺជំរុញដោយលទ្ធផលដ៏ល្អក្នុងការនាំចេញ ដែលត្រូវបានកាត់កងបញ្ច្រាសវិញដោយការធ្លាក់ចុះ តំរូវការក្នុងស្រុក និងវិនិយោគ ។ សំរាប់កូរ៉េខាងត្បូង និងតៃវ៉ាន់ ផសស ពិត នៅត្រីមាសទី៤ ២០០៤ កើនឡើងតាមអត្រាប្រចាំឆ្នាំ ៣,៣% គឺថយចុះពីកំរិត ៤,៦% និង ៥,៣% រៀងគ្នា កាលពីត្រីមាសមុន ។ កំណើន ផសស ខ្សោយ នៅកូរ៉េខាងត្បូង បណ្តាលជាសំខាន់ដោយសារការថយកំណើនក្នុងការនាំចេញ ក៏ដូចជានិន្នាការធ្លាក់ចុះក្នុងវិនិយោគខាងសាងសង់ ។ ការថយកំណើននៅតៃវ៉ាន់ មួយភាគធំគឺដោយសារការថយកំណើនក្នុងការនាំចេញ និងការឡើងថ្លៃប្រេងឆៅ និងវត្ថុធាតុដើម ។

សំរាប់អាស៊ាន៤ (សិង្ហបុរី ម៉ាឡេស៊ី ថៃ និង ឥណ្ឌូនេស៊ី) កំណើន ផសស ពិត នៅត្រីមាសទី៤ នៅមានកំរិតខ្ពស់ដល់ ៦,៥%, ៥,៦%, ៥,០%, និង ៦,៦% រៀងគ្នា ។ លើកលែងតែឥណ្ឌូនេស៊ីចេញ អត្រាកំណើនរបស់ប្រទេសទាំងនេះនៅត្រីមាសទី៤ គឺមានកំរិតទាបបន្តិច ជាងកាលពីត្រីមាសទី៣ ។ សំរាប់ម៉ាឡេស៊ី ការថយកំណើនបណ្តាលចេញពីការថយចុះយ៉ាងខ្លាំងក្នុងវិស័យកម្មន្តសាល ដោយសារតំរូវការសាកលនូវអង្គធាតុពាក់កណ្តាលចំលង (semiconductors) និងគ្រឿងអេឡិចត្រូនិកធ្លាក់ចុះ ។ សំរាប់ប្រទេសថៃ ការធ្លាក់ ចុះបណ្តាលពីការរាំងស្ងួត ការកើតមានជំងឺផ្តាសាយបក្សីសាជាថ្មី និងការ ឡើងថ្លៃប្រេងឥន្ធនៈឥតឈប់ឈរ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់ក្នុងទីផ្សារអន្តរជាតិ

នៅត្រីមាសទី៤ ២០០៤ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ៣,៣% គឺលឿនជាងនៅត្រីមាសទី៣ (២,៧%) ដោយសារការឡើងថ្លៃប្រេងឥន្ធនៈ និងការព្យាបាលសុខភាព ។ ធនាគារកណ្តាល US រំពឹងថា នឹងតំលើងថែមទៀតនូវការប្រាក់សំខាន់ៗ ដើម្បីទប់កំណើនអតិផរណាឱ្យបាន ។ នៅតំបន់អឺរ៉ូ អតិផរណា មានកំរិត ២,៣% (គឺខ្ពស់ជាងកំរិតអតិបរមារបស់ធនាគារកណ្តាលអឺរ៉ុប (ECB) ដែលកំណត់ត្រឹម ២%) ដែលឆ្លុះបញ្ចាំងពីកំណើនពន្ធលើថ្នាំជក់នៅប្រទេសអាឡឺម៉ង់ និងអ៊ីតាលី ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់កើន ០,៥% ក្នុងរយៈមួយឆ្នាំដល់ចុងត្រីមាសទី៤ គឺកើនឡើងពីកំរិត -០,១% កាលពីត្រីមាសទី៣ ។ មូលហេតុចំបងនៃនិន្នាការកើនឡើងនេះ គឺដោយសារការស្ទុះឡើងមួយរយៈខ្លីនៃថ្លៃម្ហូបអាហារស្រស់ និងការឡើងថ្លៃប្រេងឆៅ ។ អតិផរណានៅចិន មានអត្រាកំណើនប្រចាំឆ្នាំ ៣,២% គឺទាបជាងកំរិត ៥,២% កាលពីត្រីមាសមុន ។

នៅត្រីមាសទី៤ ២០០៤ ដុល្លារ US បានធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗភាគច្រើនគឺ ១ដុល្លារ US ទិញបាន ០,៧៧អឺរ៉ូ ធៀបនឹង ០,៨២អឺរ៉ូនៅត្រីមាសទី៣ ។ ម្យ៉ាងទៀត ១ដុល្លារ US ប្តូរបាន ១០៥,៩យ៉េន ដោយចុះពី ១០៩,៩យ៉េននៅត្រីមាសមុន ។ កត្តាចំបងនៃការធ្លាក់ចុះនេះគឺ អ្នកចូលរួមក្នុងទីផ្សារនៅបន្តផ្តោតការយកចិត្តទុកដាក់ទៅលើទំហំ និងការអូសបន្លាយឱនភាពពាណិជ្ជកម្ម US ហើយនិងតំរូវការហិរញ្ញប្បទានសំរាប់ឱនភាពនេះ ។

## ថ្លៃផលិតផលនៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ២០០៤ ថ្លៃផលិតផលជ្រើសរើសមួយចំនួនក្នុងទីផ្សារអន្តរជាតិ មិនឡើងចុះច្រើនទេ ។ នៅត្រីមាសទី៤ ២០០៤ ថ្លៃអង្ករស Thai 100% B ធុនលេខ២ នៅទីផ្សារបាងកក កើន ១០% ធៀបនឹងត្រីមាសមុន និងកើន ៣៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ នៅត្រីមាសទី៤ កៅស៊ូឡើងថ្លៃបានបន្តិចដែរដល់ ១.២៣៨,២ដុល្លារ/តោន រឺឡើងថ្លៃ ៤% ធៀបនឹងត្រីមាសមុន ។ ពោត និងសណ្តែកសៀង លក់នៅត្រីមាសទី៤ បានថោកជាងកាលពីត្រីមាសទី៣ ។ ពោតលក់បាន ៩៤,៤ដុល្លារ/តោន រឺចុះថ្លៃ ៨% ធៀបនឹងត្រីមាសទី៣ ២០០៤ និង ចុះថ្លៃ ១៣% ធៀបនឹងត្រីមាសទី៤ ២០០៣ ។ សណ្តែកសៀងលក់បាន ២១៦,៩ដុល្លារ/តោន គឺចុះថ្លៃ ១៤% ធៀបនឹងត្រីមាសទី៣ ២០០៤ និងចុះថ្លៃ ២៥% ធៀបនឹងត្រីមាសទី៤ ២០០៣ ។ នៅត្រីមាសទី៤ ប្រេងឆៅ និងសាំង ចុះថ្លៃបន្តិចអស់ ២% និង ១% រៀងគ្នា ធៀបនឹងត្រីមាសមុន ប៉ុន្តែ ឡើងថ្លៃសំបើមណាស់បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៣ ដល់ ៣១% និង ៤៣% រៀងគ្នា ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង គីម វុនស៊ីណារិទ្ធិ*

## តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើសពីឆ្នាំ២០០០-២០០៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | 2003 | | 2004 | | | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | - | - | - | - | - | - | - | 5.0 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.8 | 3.9 | 4.3 | 4.5 | 4.3 | 5.0 | 6.6 | 4.1 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 5.4 | 3.5 | 6.4 | 7.6 | 8.0 | 6.8 | 5.6 | 5.3 |
| សិង្ហបុរី | 9.5 | -2.3 | 3.0 | 1.7 | 3.7 | 7.5 | 12.5 | 7.5 | 6.5 | 1.1 |
| ថៃ | 4.4 | 1.9 | 6.0 | 6.6 | 7.8 | 6.5 | 6.3 | 6.0 | 5.0 | 6.7 |
| វៀតណាម | | 6.0 | - | - | - | - | - | - | - | 7.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.1 | 9.1 | 9.9 | 9.7 | 9.6 | 9.1 | 9.5 | 9.1 |
| ហុងកុង | 10.2 | 0.5 | 4.8 | 4.0 | 4.9 | 6.8 | 12.1 | 7.2 | 7.1 | 3.2 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 6.8 | 2.3 | 3.9 | 5.3 | 5.5 | 4.6 | 3.3 | 3.1 |
| តៃវ៉ាន់ | 5.8 | -2.2 | 4.2 | 4.2 | 5.4 | 6.3 | 7.7 | 5.3 | 3.3 | 3.2 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 3.5 | 1.4 | 1.3 | 0.3 | 0.6 | 1.5 | 2.2 | 1.9 | 1.6 | 0.6 |
| ជប៉ុន | 2.8 | 0.4 | 1.7 | 1.9 | 3.1 | 5.6 | 4.4 | 2.6 | 0.8 | 2.5 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 2.8 | 3.6 | 4.3 | 5.0 | 4.7 | 3.9 | 3.8 | 3.1 |

## តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | | | | 2004 | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.8 | -0.6 | 3.2 | 0.7 | 0.5 | 0.7 | 2.2 | 6.5 | - | 1.2 |
| ឥណ្ឌូនេស៊ី | 3.7 | 11.5 | 11.9 | 5.6 | 3.7 | 4.9 | 6.7 | 7 | - | 6.7 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.8 | 1.0 | 1.2 | 1.0 | 1.2 | 1.4 | 2.1 | 1.1 |
| សិង្ហបុរី | 1.4 | 1.0 | -0.4 | 0.5 | 0.6 | 1.4 | 1.9 | 1.7 | 1.7 | 0.5 |
| ថៃ | 1.5 | 1.7 | 0.6 | 1.9 | 1.6 | 1.9 | 2.6 | 3.3 | 3.1 | 1.8 |
| វៀតណាម | -1.7 | -0.4 | 3.8 | 3.5 | 2.2 | - | - | - | - | 3.1 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 0.9 | -0.7 | 0.8 | 2.7 | 2.8 | 4.4 | 5.2 | 3.2 | 1.2 |
| ហុងកុង | -3.6 | -1.3 | -3.0 | -3.7 | -2.3 | -1.9 | -0.8 | 0.8 | 0.2 | -2.6 |
| កូរ៉េខាងត្បូង | 2.3 | 4.4 | 2.7 | 3.2 | 3.5 | 2.7 | 3.3 | 4.4 | 3.4 | 3.5 |
| តៃវ៉ាន់ | 1.3 | -0.01 | -0.2 | - | - | - | - | - | | -0.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 2.3 | 2.6 | 2.2 | 2.0 | 2.1 | 1.8 | 2.3 | 2.3 | 2.3 | 2.1 |
| ជប៉ុន | -0.7 | -0.6 | -0.9 | -0.2 | -0.3 | -0.1 | -0.3 | -0.1 | 0.5 | -0.3 |
| សហរដ្ឋអាមេរិក | 3.3 | 2.8 | 1.6 | 2.2 | 1.9 | 1.8 | 2.9 | 2.7 | 3.3 | 2.3 |

## តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | | | | 2004 | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,840.8 | 3,916.3 | 3,912.1 | 3,998.3 | 3,987.0 | 3,990.3 | 4,005.3 | 4,034.7 | 4,034.7 | 3,973 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8,421 | 10,261 | 9,311 | 8,441 | 8,482 | 8,469 | 9,001 | 9,156 | 9,128 | 8,577 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.79 | 1.75 | 1.72 | 1.69 | 1.70 | 1.70 | 1.65 | 1.74 |
| ថៃ (បាត) | 40.1 | 44.4 | 42.9 | 41.3 | 39.7 | 39.1 | 40.2 | 41.3 | 40.3 | 41.5 |
| វៀតណាម (ដុង) | 14,168 | 14,725 | 15,280 | 15,522 | 15,618 | 15,717 | 15,735 | 16,262 | - | 15,510 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.79 | 7.75 | 7.77 | 7.80 | 7.80 | 7.78 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,251 | 1,174 | 1,182 | 1,171 | 1,162 | 1,155 | 1,093 | 1,192 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.2 | 33.8 | 34.5 | 34.2 | 33.9 | 33.3 | 33.3 | 33.9 | 32.9 | 34.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ (អឺរ៉ូ) | 1.09 | 1.12 | 1.06 | 0.89 | 0.84 | 0.80 | 0.83 | 0.82 | 0.77 | 0.89 |
| ជប៉ុន (យ៉េន) | 107.8 | 121.5 | 125.4 | 117.6 | 108.9 | 107.2 | 109.7 | 109.9 | 105.9 | 115.9 |

## តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០០-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | | 2004 | | | | 2003 |
|---|---|---|---|---|---|---|---|---|---|---|
| | | | Q4 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | |
| ឈើមូលប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 88.4 | 89.5 | 108.3 | 100.4 | 108.3 | 122.6 | 128.8 | 102.3 | 94.4 | 105.2 |
| ឈើអារប្រភេទរឹង - ម៉ាឡេស៊ី ($/ម៣) | 310.2 | 285.7 | 428.3 | 408.7 | 199.3 | 527 | 497 | 432.3 | 429 | 443.2 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 834.1 | 1,017.4 | 1,261.4 | 1,246.4 | 1,333.4 | 1,190.6 | 1238.2 | 1,050 |
| អង្ករ - បាងកក ($/តោន) | 206.7 | 177.3 | 192.2 | 200.3 | 198.7 | 231.4 | 240.7 | 240.5 | 264.9 | 200.8 |
| សណ្តែកសៀង - សហរដ្ឋអាមេរិក ($/តោន) | 193 | 180.7 | 220 | 212.4 | 290.2 | 331.7 | 356.4 | 251.1 | 216.5 | 241.3 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 26.2 | 26.5 | 27 | 29.3 | 33.3 | 36.09 | 35.5 | 26.8 |
| មាស – London ($/troy ounce) | 21.1 | 19.5 | 19 | 23.6 | 22.2 | 27.4 | 32.1 | 32.1 | 31.8 | 23 |

*ប្រភព: តារាង ១: The Economist, ការិយាល័យស្ថិតិជាតិ និងធនាគារកណ្តាលនានា, មជ្ឈមណ្ឌលពត៌មានតំបន់អាស៊ីរបស់ADB, តារាង ២. IMF, The Economist, តារាង ៣: IMF, The Economist, NBC. តារាង ៤: FAO, រដ្ឋបាលពត៌មានថាមពល US ។*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទីបួន ២០០៤ វិស័យទេសចរណ៍បានរួមចំណែកខ្លាំងជាងមុនដល់សេដ្ឋកិច្ចកម្ពុជា បើធៀបនឹងវិស័យសាងសង់ រឺបើធៀបនឹងត្រីមាសទីបី ។ នៅត្រីមាសទីបួន ២០០៤ ការនាំចេញសំលៀកបំពាក់បានឡើងដល់កំរិតកំពូល ដោយសារឈ្មួញនាំចេញខិតខំប្រើប្រាស់កូតាឱ្យបានច្រើនបំផុតនៅមុនការបញ្ចប់កិច្ចព្រមព្រៀងលើក្រណាត់គ្រប់មុខ (MFA) នាពេលដ៏ខ្លីខាងមុខ ។

នៅត្រីមាសទីបួន ឆ្នាំ២០០៤ កម្ពុជាទាក់ទាញភ្ញៀវបរទេស បាន ៣១១.០០០នាក់ រឺ ៣៦% ខ្ពស់ជាងត្រីមាសទីបី ក្នុងនេះភ្ញៀវបរទេសចូលមកតាមផ្លូវអាកាសកើន ៤០% ដល់ ២០១.៥០០ នាក់ ។ ដោយឡែកអាកាសយានដ្ឋានអន្តរជាតិសៀមរាប ទទួលភ្ញៀវចូលបាន ១១០.២១៩ នាក់ដែលបង្ហាញពីកំណើន ៥៨% ។ តួលេខនេះគឺខ្ពស់ជាងចំនួនភ្ញៀវ មកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញដែលកើនត្រឹម ២៣% ដល់ ៩១.២៨៥ នាក់ ។ ភ្ញៀវឆ្លងកាត់ច្រកទ្វារព្រំដែនអន្តរជាតិចូលមកកម្ពុជា កើន ៣០% ដល់ ១០៩.៥០០នាក់ ក្នុងនេះ ៦៥,៥% ឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត (ជាប់ព្រំដែនថៃ) និង ១៥% ចូលតាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត (ជាប់ព្រំដែនវៀតណាម) ។

យោងតាមក្រសួងទេសចរណ៍ ចំនួនទេសចរបរទេសសរុបនៅឆ្នាំ២០០៤ គិតទាំងទេសចរទៅព្រះវិហារផង មាន ១.០៥៥.២០២នាក់ រឺកើន ៥១% ពីចំនួន ៧០១.១០៤នាក់នៅឆ្នាំ២០០៣ ។ នៅឆ្នាំ២០០៤ មានការហោះហើរផ្ទាល់បីថែមទៀត មកកាន់ខេត្តសៀមរាប គឺមកពី ជប៉ុន (ណារីតា) ចិន និងយ៉ង់ហ្គោន ។ រយៈពេលស្នាក់នៅជាមធ្យម កើនដល់ ៦,៣ថ្ងៃនៅឆ្នាំ ២០០៤ ពីកំរិត ៥,៥ថ្ងៃនៅឆ្នាំ២០០៣ ប៉ុន្តែចំណាយប៉ាន់ស្មានក្នុងមួយថ្ងៃសំរាប់ទេសចរម្នាក់ថយចុះមកត្រឹម ៨៧ ដុល្លារនៅឆ្នាំ ២០០៤ ពីកំរិត ៩០ដុល្លារនៅឆ្នាំ២០០៣ ។ តាមនេះ ចំណាយសរុបរបស់ទេសចរបរទេសនៅឆ្នាំ២០០៤ មានចំនួន ៥៧៨លានដុល្លារ ដោយកើនពីកំរិត ៣៤៧លានដុល្លារនៅឆ្នាំ២០០៣ ។

ការសាងសង់ដែលជាអនុវិស័យចំបងលំដាប់ទីពីរនៃឧស្សាហកម្ម ហាក់ដូចបានធ្លាក់ចុះ ដោយមានការថយចុះ ១៨% ពីត្រីមាសទីបី ដល់ ទីបួន ២០០៤ ក្នុងតំលៃគំរោងសាងសង់ដែលសាលាក្រុងភ្នំពេញបានអនុម័ត ។ ប៉ុន្តែការសាងសង់ផ្ទះល្វែង ដែលជាសមាសភាគធំជាងគេ បន្តកើនឡើងក្នុងរយៈពេលនេះ (ដល់ ៤៦,៣លានដុល្លារនៅត្រីមាសទីបួន ពី ៤៤,៣លានដុល្លារនៅត្រីមាសទីបី) ។ បើធៀបនឹងត្រីមាសទីបី ២០០៣ វិស័យសាងសង់កើនបាន ២៩% ។

យោងតាមធនាគារជាតិនៃកម្ពុជា ឥណទានផ្តល់ដោយធនាគារពាណិជ្ជសំរាប់សកម្មភាពសាងសង់ មាន ២៤,២លានដុល្លារ នៅត្រីមាសទីបួនឆ្នាំ២០០៤ រឺ ១៦% ទាបជាងកាលពីត្រីមាសមុន ប៉ុន្តែត្រូវជា ១៧% ខ្ពស់ជាងត្រីមាសដូចគ្នា ឆ្នាំ២០០៣ ។

វិនិយោគឯកជនដែលបានអនុម័តគិតជាទ្រព្យសកម្មជាប់លាប់ បានធ្លាក់ចុះយ៉ាងខ្លាំងអស់ ៨០% មកត្រឹម ១៦,៤លានដុល្លារនៅត្រីមាសទីបួន ២០០៤ ពីកំរិត ៨២លានដុល្លារនៅត្រីមាសទីបី ។ ការធ្លាក់ចុះនេះនាំមុខជាសំខាន់ដោយការធ្លាក់ចុះយ៉ាងខ្លាំងនៃវិនិយោគឯកជនខាងកសិកម្ម និងវិស័យសេវាកម្ម (ចុះដល់សូន្យនៅត្រីមាសទីបួន ពីកំរិត ៣លានដុល្លារ និង ៦,៤លានដុល្លាររៀងគ្នានៅត្រីមាសទីបី) ។ ម្យ៉ាងទៀត វិនិយោគឯកជនខាងឧស្សាហកម្មធ្លាក់ចុះ ៧៨% ដល់ ១៦,៤លានដុល្លារនៅត្រីមាសទីបួន ក្នុងនេះ ១២,៧លានដុល្លារគឺជាវិនិយោគក្នុងវិស័យកាត់ដេរដែលបានធ្លាក់ចុះពីកំរិត ៤៤លានដុល្លារកាលពីត្រីមាសទីបី ។

នៅឆ្នាំ២០០៤ គំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ដែលបានអនុម័ត មានតំលៃ ២៧៥លានដុល្លារ គឺធ្លាក់ចុះអស់ ១៤% ធៀបនឹងឆ្នាំ២០០៣ ។ គំរោងវិនិយោគថ្មីដែលបានអនុម័ត មានតំលៃ ២១៧លានដុល្លារ ដោយធ្លាក់ចុះពីកំរិត ២៥០លានដុល្លារនៅឆ្នាំ២០០៣ ។ ប៉ុន្តែវិនិយោគថ្មីខាងវិស័យកាត់ដេរកើនឡើងជាងពីរដងដល់ ៧២លានដុល្លារធៀបនឹងឆ្នាំ២០០៣ ដែលមានតែ ២៧,៦លានដុល្លារ ហើយវិនិយោគពង្រីកសមត្ថភាពក្នុងវិស័យនេះ ធ្លាក់ចុះបន្តិចអស់ ៥,៤% ។

ជញ្ជីងពាណិជ្ជកម្មកម្ពុជាមានឱនភាព ៣,៤លានដុល្លារនៅត្រីមាសទីបួន ២០០៤ ធៀបនឹងអតិរេកពាណិជ្ជកម្មចំនួន ១៤០,៨លានដុល្លារនៅត្រីមាសទីបី ។ ប៉ុន្តែឱនភាពនេះមានកំរិត ៧១% ទាបជាងឱនភាពនៅត្រីមាសដូចគ្នាឆ្នាំមុន ។

យោងតាមទីចាត់ការគយនិងរដ្ឋាករ នៅត្រីមាសទីបួន ២០០៤ តំលៃនៃការនាំចេញមានចំនួន ៥៤៥,១លានដុល្លារ រឺធ្លាក់ចុះ ១៨,៥% បើធៀបនឹងត្រីមាសមុន ។ ការធ្លាក់ចុះបណ្តាលជាសំខាន់ពី ការធ្លាក់ចុះសំលៀកបំពាក់នាំចេញអស់ ១៩% មកត្រឹម ៥២០,៣លានដុល្លារ ។ នៅឆ្នាំ២០០៤ ការនាំចេញមានតំលៃសរុប ២.១០៨លានដុល្លារ រឺកើន ២៣% ពីកំរិត ១.៧០៨លានដុល្លារនៅឆ្នាំ២០០៣ ។ ផលិតផលសំលៀកបំពាក់នាំចេញមានតំលៃ ២.០២៧លានដុល្លារ រឺ ២៤,៥% ខ្ពស់ជាងឆ្នាំមុន ។ ក្នុងនេះ ៦៣% បាននាំចេញទៅសហរដ្ឋអាមេរិក (US) (កំណើន ១៦%) និង ២៩% ទៅសហភាពអឺរ៉ុប (EU) (កំណើន ៤២%) ។

ពីត្រីមាសទីបី-ទីបួន ២០០៤ តំលៃនៃការនាំចូលកើនបន្តិចបាន ៤% ដល់ ៥៤៨,៥លានដុល្លារ ក្នុងនេះទំនិញចំបងៗ មានជាអាទិ៍ យានយន្តដែលកើន ២៧,៦% ដល់ ៣៤,៧លានដុល្លារ, សំភារៈសំណង់កើន ២៤,៣% ដល់ ២៦,៥លានដុល្លារ, និងម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ កើន ១៩,៦% ដល់ ៧៩,៨លានដុល្លារ ។ កំណើនទាំងនេះត្រូវបានកាត់កងមកវិញជាសំខាន់ដោយការធ្លាក់ចុះ ការនាំចូលគ្រឿងអេឡិចត្រូនិក និងផលិតផលថាមពលអស់ ៤៤,៤% មកត្រឹម ២,៤លានដុល្លារ និង ១៤,៦% មកត្រឹម ៤២,២លានដុល្លាររៀងគ្នា ។ នៅឆ្នាំ២០០៤ តំលៃទំនិញនាំចូលសរុបកើនដល់ ២.១៤២,៥លានដុល្លារ ពី ១.៨២៥ លានដុល្លារនៅឆ្នាំមុន (កំណើន ១៧,៤%) ។ ការនាំចូលរថយន្ត និងរថយន្តក្រុងកើនជិតមួយជាពីរនៅឆ្នាំ២០០៤ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទីបួន ២០០៤ រដ្ឋាភិបាលមានឱនភាពថវិកា ២៤៧ពាន់លានរៀល ធៀបនឹង ២៥១ពាន់លានរៀលនៅត្រីមាសមុន ។ ដោយឡែកចំណូលថវិកាឡើងដល់ ៦៦២ពាន់លានរៀល រឺ កំណើន ៤៦% ក្នុងរយៈពេលនេះ ។ ចំណូលពន្ធកើន ៤៥% ដល់ ៤៨៥,៧ពាន់លានរៀលក្នុងនេះចំណូលពី ពន្ធគយ អាករពិសេស និង អាករលើតំលៃបន្ថែម មានចំណែករួមគ្នា ៩១%នៃចំណូលពន្ធសរុប ដោយកើន ៦៨% ដល់ ១៦៨ពាន់លានរៀល, ៤៥% ដល់ ៩០,៧ពាន់លានរៀល, និង ៣៧% ដល់ ១៨៤ពាន់លានរៀលរៀងៗគ្នា ។ ក្នុងពេលជាមួយគ្នា ចំណូលមិនមែនពន្ធ ក៏កើន ៤៧% ដែរ

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ដល់ ១៧២ពាន់លានរៀល ។ ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៤ ចំណូលថវិកាសរុបសំរេចបាន ១០០% នៃផែនការ ដោយឡើង ដល់ ២.១២៦,៧ពាន់លានរៀល ធៀបនឹង ១.៧៦៤,៦ពាន់លានរៀលនៅឆ្នាំ២០០៣ ដែលកាលនោះសំរេចបានតែ ៨៨% នៃផែនការ ។

ចំណាយរដ្ឋាភិបាល (រួមទាំងការកែតំរូវចំណាយផង) ឡើងដល់ ៩០៩ពាន់លានរៀលនៅត្រីមាសទី៤ ២០០៤ រឺ ២៩% ខ្ពស់ជាងត្រីមាសមុន ។ ចំណាយចរន្តកើន ៤៥%ដល់ ៦១៥,៨ពាន់លានរៀល ហើយចំណាយមូលធនក៏កើន ៦% ដែរ ដល់ ២៩៣,៥ពាន់លានរៀល ។ នៅឆ្នាំ២០០៤ ចំណាយថវិកាសរុប (រួមទាំងការកែតំរូវចំណាយផង) ឡើងដល់ ២.៩៩១លានរៀល រឺ ៩% ច្រើនជាងឆ្នាំ២០០៣ ។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

ទិន្នន័យប្រមូលបានប្រចាំខែដោយវិជ្ជាស្ថានជាតិស្ថិតិ បង្ហាញថា ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញធ្លាក់ចុះអស់ ០,៨% ពីខែតុលា-ធ្នូ ២០០៤ ក្រោយពីមានកំណើនចំនួន ៤,៥% នៅត្រីមាសមុន ។ ការធ្លាក់ចុះនេះនាំមុខដោយការចុះថ្លៃអាហារ ៣% ថ្វីបើមានកំណើនថ្លៃសេវាដឹកជញ្ជូន និងទូរគមនាគមន៍ក្តី ។ គិតជាបំរែបំរួលពីមួយឆ្នាំទៅមួយឆ្នាំ អត្រាអតិផរណានៅភ្នំពេញនៅត្រីមាសទីបួនគឺ ៥,៨% ធៀបនឹង ៦,៧% នៅត្រីមាសទីបី ។ គិតលើមូលដ្ឋានប្រចាំឆ្នាំ អត្រាអតិផរណា (ជារៀល) នៅភ្នំពេញកើនដល់ប្រហែល ៤% នៅឆ្នាំ២០០៤ ធៀបនឹង ១,២% នៅឆ្នាំ២០០៣ ដោយសារតែកំណើនថ្លៃម្ហូបអាហារ និងថាមពល ។

*ចំណូលប្រចាំថ្ងៃពិតរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៣០% មកត្រឹម ៣.៥៧៨រៀល ពីកំរិត ៥.១២៤រៀលនៅខែកុម្ភៈឆ្នាំមុន ។ ការរាំងស្ងួតធ្ងន់ធ្ងរនៅឆមាសទីពីរ ឆ្នាំ២០០៤ ក្នុងទូទាំងប្រទេស អាចជាមូលហេតុនៃការធ្លាក់ចុះនេះ ។*

យោងតាមធនាគារជាតិនៃកម្ពុជា អត្រាប្តូរប្រាក់រៀល-ដុល្លារUS នៅត្រីមាសទី៤ ឆ្នាំ ២០០៤ ស៊ឹងគ្មានការប្រែប្រួល បើប្រៀបធៀបនឹងត្រីមាសទី៣ ប៉ុន្តែបានចុះថ្លៃទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ។ ប្រាក់រៀលប្តូរបាន ៤.០៣៤,៧រៀល/ដុល្លារ នៅត្រីមាសទី៣ និងទី៤ ហើយវាប្តូរបាន ១០០,១រៀល/បាតនៅត្រីមាសទី៤ ២០០៤ រឺចុះថ្លៃ ២,៥% បើធៀបនឹងត្រីមាសទី៣ ។ ក្នុងរយៈពេលដដែល ប្រាក់រៀលក៏ចុះថ្លៃអស់ ២% ដែរ ទល់នឹងប្រាក់ដុងវៀតណាមដោយប្តូរបាន ២៥,៣រៀល/១០០ដុង នៅត្រីមាសទី៤ ឆ្នាំ២០០៤ ។

## ការវិវត្តន៍រូបិយវត្ថុ

ក្នុងវិស័យធនាគារ រូបិយវត្ថុទូទៅ (M2) មាននិន្នាការកើនឡើងចាប់តាំងពីចុងត្រីមាសទីបី ឆ្នាំ២០០៣ ។ រូបិយវត្ថុទូទៅកើន ៣,៨% ដល់ ៤.៣២៩ ពាន់លានរៀល (១.០៧៤លានដុល្លារ) នៅចុងត្រីមាសទីបួន ឆ្នាំ២០០៤ គឺយឺតជាងត្រីមាសមុនដែលមានកំណើន ៨,៥% ។ រឿងនេះ បង្ហាញពីកំណើនយឺតជាងមុននៃប្រាក់បញ្ញើជារូបិយវត្ថុបរទេស ត្រឹម ៣,៥% ដល់ ៧៦៣,៨ លានដុល្លារនៅត្រីមាសទីបួន, ធៀបនឹងកំណើន ១០% នៅត្រីមាសទីបី ។

នៅកំឡុងរយៈពេល ១២ខែ រូបិយវត្ថុទូទៅកើនឡើងគួរអោយកត់សំគាល់ដល់ ៣០% ។ សមាភាគប្រាក់រៀល កើនឡើង ២៣% ក្នុងនេះប្រាក់រៀល ចរាចរនៅក្រៅធនាគារ កើនបាន ២៣% ដែលបង្ហាញពីកំណើន ១៨,៥% នៃការបោះផ្សាយក្រដាសប្រាក់ ។ នៅពេលដូចគ្នានេះ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៣៣% ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលកររងាយរងគ្រោះ (អង្កេតថ្ងៃទី ១-១៥ កុម្ភៈ ២០០៥)

ការរាំងស្ងួតដ៏ធ្ងន់ធ្ងរនៅឆមាសទីពីរ ២០០៤ បានប៉ះពាល់ដល់ដីស្រែជាង ៥០០.០០០ហ.ត រឺ ១០% នៃដំណាំស្រូវនៅកម្ពុជា (Reuters November 25, 2004) ហើយធ្វើអោយជីវភាពរស់នៅរបស់អ្នកក្រកាន់តែយ៉ាប់យ៉ឺន ជាពិសេសនៅតាមជនបទ ។ អង្កេតពីថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ធ្វើឡើងដោយ វសបអ លើពលកររងាយរងគ្រោះ ១០ក្រុម បានបង្ហាញថា ចំណូលប្រចាំថ្ងៃពិតរបស់អ្នកស៊ីឈ្នួលធ្វើស្រែ នៅក្នុងខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ធ្លាក់ចុះយ៉ាងខ្លាំង អស់ ៣០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ទិន្នន័យក្នុងពេលកន្លងមក ក៏បង្ហាញដែរថា ចំនួនពលកររងាយរងគ្រោះនៅភ្នំពេញ ដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅខេត្តផ្សេង កើនពីកំរិត ៨៥% នៅខែសីហា ឆ្នាំ២០០៤ ដល់ ៨៨% នៅខែកុម្ភៈ ឆ្នាំ២០០៥ ។ ចំណូលប្រចាំថ្ងៃពិតរបស់ក្រុមពលកររងាយរងគ្រោះភាគច្រើន បានថយចុះ លើកលែងតែអ្នករើសអេតចាយ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់ ។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៥ កម្មករកាត់ដេរមានចំណូលប្រចាំថ្ងៃពិត ៩.២១៣រៀល គឺថយចុះអស់ ១,២% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០០៤ ហើយនេះជាការថយចុះតូចជាងគេ ក្នុងចំណោមក្រុមនានាដែលមានចំណូលថយចុះ ថ្វីបើមានអ្នកឆ្លើយសំភាសន៍ ៨០% បានរាយការណ៍ថា មានការកាត់បន្ថយការធ្វើការម៉ោងបន្ថែម ដោយសាររោងចក្រថយសកម្មភាព ។ ពីឆ្នាំ២០០០ ដល់ ២០០៣ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ មានការឡើងចុះយ៉ាងខ្លាំងពីកំរិត ៦.៧០១រៀល ទៅ ៩.៩៦២រៀល ហើយក្នុងឆ្នាំ២០០៤ វានៅថេរត្រឹមប្រហែល ៩.៣០០រៀល ។

ទោះបីជាអ្នកឆ្លើយសំភាសន៍ភាគច្រើនអះអាងថា អ្នករត់ម៉ូតូឌុបបានកើនចំនួនបើធៀបនឹងកាលពីមួយឆ្នាំមុនក្តី ក៏ចំណូលប្រចាំថ្ងៃពិតរបស់ពួកគាត់បានកើន ៩% ពី ១០.៧៩១រៀលនៅខែកុម្ភៈ ឆ្នាំ២០០៤ ដល់ ១១.៧៦៧រៀល នៅខែកុម្ភៈ ២០០៥ ។ កំណើនភ្លាមៗ នៃទេសចរមកភ្នំពេញ (ចំនួនទេសចរមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប កើនដល់ ៨០.៨២០នាក់នៅខែមករា ឆ្នាំ២០០៥ ដែលជាចំនួនខ្ពស់បំផុតក្នុងកំឡុងពេល ១៣ឆ្នាំនេះ) និងតំរូវការខ្លាំងនៅក្នុងបុណ្យចូលឆ្នាំចិន អាចជាមូលហេតុនៃកំណើនចំណូលខាងលើ ។ បើធៀបនឹងខែវិច្ឆិកា ២០០៤ ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប កើនបាន ៣៥% ។ ទិន្នន័យអង្កេតក៏បញ្ជាក់គាំទ្រដែរ ដោយមានអ្នកឆ្លើយសំភាសន៍ ៥៧% បានរាយការណ៍ថា ចំណូលប្រចាំថ្ងៃពិតរបស់ពួកគាត់បានកើនឡើងមែន ។

ចាប់តាំងពីខែសីហា ២០០៤ មក អ្នកស៊ីឈ្នួលធ្វើស្រែបានថយចុះ ចំណូលប្រចាំថ្ងៃពិត ។ នៅខែកុម្ភៈ ២០០៥ ចំណូលប្រចាំថ្ងៃពិតរបស់ពួកគាត់ធ្លាក់ចុះយ៉ាងខ្លាំង អស់ ៣០% មកត្រឹម ៣.៥៧៨រៀល ពីកំរិត ៥.១២៤រៀលនៅខែកុម្ភៈឆ្នាំមុន ។ ការរាំងស្ងួតធ្ងន់ធ្ងរនៅឆមាសទីពីរ ២០០៤ ក្នុងទូទាំង

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

ប្រទេស អាចជាមូលហេតុនៃការធ្លាក់ចុះនេះ ។ ក្នុងពេលជាមួយគ្នា ចំណូលប្រចាំថ្ងៃពិតរបស់កម្មករលីសែង អ្នកលក់បន្លែតូចតាច និងកម្មករសំណង់គ្មានជំនាញ ក៏ធ្លាក់ចុះយ៉ាងខ្លាំងដែរ ធៀបនឹងកាលពីមួយឆ្នាំមុន គឺធ្លាក់ ១៧,៣% ១០,៤% និង ១៧,២% រៀងគ្នា ។ ចំណុចដ៏ប្លែកមួយ គឺចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយកើនបាន ១៦,៤% បើធៀបនឹងកាលពីមួយឆ្នាំមុន ។

ក្រោយពីបានធ្លាក់ចុះនៅខែវិច្ឆិកា ២០០៤ ដល់កំរិតទាបបំផុតក្នុងកំឡុង ៧ឆ្នាំ ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ កើនដល់ ៨.៥២៩រៀល នៅខែកុម្ភៈ ២០០៥ ។ ប៉ុន្តែបើធៀបនឹងខែកុម្ភៈ ២០០៤ វាថយចុះ ៦,៨% ដែលបង្ហាញជាសំខាន់ថា អ្នកធាក់ស៊ីក្លូមានចំនួនកាន់តែច្រើន ។ នៅខែកុម្ភៈ ឆ្នាំ២០០៥ ចំណូលប្រចាំថ្ងៃពិតរបស់អ្នកបំរើតាមភោជនីយដ្ឋាន ក៏ធ្លាក់ចុះអស់ ៥,៣% ដែរ បើធៀបនឹងមួយឆ្នាំមុន ប៉ុន្តែ វាកើនឡើងមួយជាពីរក្នុងរយៈពេល ៥ឆ្នាំនេះ ចាប់ពី ១.៩១៤រៀល នៅខែកុម្ភៈ ឆ្នាំ២០០០ ដល់ ៤.៤៧០រៀល នៅខែកុម្ភៈ ឆ្នាំ២០០៥ ហើយនាំអោយយើងទទួលស្គាល់ថាអាជីវកម្មភោជនីយដ្ឋាន កម្ពុជាមានការរីកចំរើនគួរកត់សំគាល់ ។

នៅខែកុម្ភៈ ២០០៥ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញឡើងដល់ ១៤.៣៦៧រៀល រឺ កើន ៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន ហើយវាបង្ហាញពីតំរូវការជាបន្តនៃវិស័យសាងសង់ដែលកំពុងរីកលូតលាស់ ។ យោងតាមអង្កេតនៅខែកុម្ភៈ ឆ្នាំ២០០៥ កម្មករសំណង់ ៥០% រៀនចប់បឋមសិក្សា ហើយ ៥០% ទៀត បានចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ ។ ការអប់រំហាក់ដូចជាដើរតួយ៉ាងសំខាន់ នៅក្នុងការជ្រើសមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ។ កម្មករសំណង់មានកំរិតអប់រំល្អ (រៀនដល់មធ្យមសិក្សាបឋមភូមិ) រកចំណូលបានជាមធ្យម ១៥.៣១៤ រៀលក្នុងមួយថ្ងៃ រឺ ១៦% ច្រើនជាងអ្នកបានរៀនត្រឹមចប់បឋមសិក្សា (១៣.១៨១រៀល) ។

*រៀបរៀងដោយៈ អ៊ុច ច័ន្ទតារានី*
*ប៊ុន ដូរីណា*

---

តពីទំព័រ ៤ # ដំណើរការកសាងប្រព័ន្ធតាមដាន...

ក្រាហ្វិក១ បង្ហាញពី អត្រាភាពក្រីក្រតាមឃុំ នៅក្នុងតំបន់សិក្សា ។ នៅស្រុកឯកភ្នំ អត្រាភាពក្រីក្រមធ្យមក្នុងឃុំទាំង៣ គឺ ៤៣,២% ឯនៅស្រុកស្ទួល ៥៣,៥% គឺបានន័យថា ស្រុកស្ទួល ក្រជាង ស្រុកឯកភ្នំ ។ លក្ខណៈសំគាល់នៃឃុំក្រៗជាងគេ គឺនៅឆ្ងាយដាច់ស្រយាល ផ្លូវមិនល្អ គ្មានសាលារៀន គ្មានមន្ទីរពេទ្យ គ្មានផ្សារ គ្មានប្រព័ន្ធស្រោចស្រព គ្មានឥណទានផ្លូវការ មានទឹកជំនន់ និងមានដីកសិកម្មតិចតួច ។

## ការអភិវឌ្ឍន៍សមត្ថភាពក្នុងមូលដ្ឋាន និងចំណងទាក់ទង

CBPMS បានជួយអភិវឌ្ឍសមត្ថភាពអាជ្ញាធរមូលដ្ឋាន ក្នុងការធ្វើផែនការគ្រប់គ្រង កេណ្ឌប្រមូល និងបែងចែកធនធាន ។ ឃុំទាំង ៦ ក្នុងតំបន់សិក្សា ឥឡូវនេះ អាចមានរបាយការណ៍តាមដានពីភាពក្រីក្រក្នុងឃុំ ដែលមានលំអិតតាមភូមិ ហើយអាជ្ញាធរមូលដ្ឋានមានសមត្ថភាពធ្វើ CBPMS ក្នុងឃុំរបស់ខ្លួនបាន ។ នៅពេលឡើងរាយការណ៍ក្នុងសិក្ខាសាលាថ្នាក់ស្រុកនឹងថ្នាក់ជាតិ អ្នកដឹកនាំក្រុមប្រឹក្សាឃុំនៅក្នុងតំបន់សិក្សា បានស្នើសុំឱ្យបន្តធ្វើ CBPMS ។ ពួកគាត់បានប្រកាសថា នឹងប្រើប្រាស់ទិន្នន័យ CBPMS នៅក្នុងផែនការបីឆ្នាំរំកិល ដែលជាចំណែកមួយនៃការងារវិមជ្ឈការសំរបសំរួលដោយកម្មវិធីសិលា ។ ពួកគាត់ក៏បានចែករំលែកព័ត៌មាន CBPMS ស្ដីពីការងារសុខាភិបាល ការងារអប់រំ និងការងារកសិកម្មដល់ NGOs នានាក្នុងស្រុកគាត់ផងដែរ ។

ទិន្នន័យ CBPMS ទទួលមកពីគំរោងសាកល្បង បានបង្កើតជាចំណងទាក់ទងមួយរវាងផែនការឃុំ ខេត្ត និងជាតិ ។ ជាជោគជ័យនៃការងារតស៊ូមតិគាំទ្រ គំរោងសាកល្បង CBPMS, ក្រសួងផែនការបានរៀបចំវេទិកាជាតិមួយស្ដីពីការរកសំគាល់ជាមុននូវគ្រួសារក្រីក្រ នៅថ្ងៃ ២៨ កុម្ភៈ ២០០៥ ដែលជាកិច្ចប្រឹងប្រែងដ៏មានប្រយោជន៍ ដើម្បីពិភាក្សាពីវិធីសាស្ត្រសំរាប់សំគាល់រកមើលគ្រួសារក្រីក្រ ។

### សិន្និដ្ឋាន

គំរោងសាកល្បង CBPMS បានអនុវត្តមើលហើយ ។ វាបានផ្ដល់លទ្ធផលដ៏មានតំលៃជាច្រើន ដោយពិពណ៌នាពីរូបភាពផ្សេងៗនៃភាពក្រីក្រក្នុង ៦ឃុំនៅ ២ខេត្ត ដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ខុសគ្នាស្រឡះ ។ ទិន្នន័យ CBPMS បានបង្កើនចំណងទាក់ទងរវាងការធ្វើផែនការនៅថ្នាក់ឃុំ ខេត្ត និងជាតិ ។ គំរោងបានអភិវឌ្ឍសមត្ថភាពអាជ្ញាធរមូលដ្ឋានក្នុងការអនុវត្តន៍ និងទទួលខុសត្រូវលើការធ្វើបច្ចុប្បន្នភាព CBPMS ក្នុងកន្លែងខ្លួន ។ ឃុំទាំង៦ ក្នុងគំរោងសាកល្បង អាចកសាងសៀវភៅស្ថិតិភាពក្រីក្ររបស់ខ្លួនបានដែលអាចប្រើការក្នុងការធ្វើផែនការ និងការតាមដាន ។ ក្រៅពីអត្រាភាពក្រីក្រនៅកំរិតភូមិ គំរោងនេះបានផ្ដល់ស្ថិតិដែលកសាងឡើងតាមរបៀបវិទ្យាសាស្ត្រអំពីប្រជាសាស្ត្រ ការអប់រំ ផ្ទះសំបែង ដីធ្លី ទឹក សុខភាព ចំនាយក្នុងគ្រួសារ មុខរបរ ចំនូល ទ្រព្យសម្បត្តិ សត្វចិញ្ចឹម និងអំពើហិង្សាក្នុងគ្រួសារ ។ លទ្ធផលរកឃើញត្រូវបានផ្សព្វផ្សាយយ៉ាងទូលាយ សំរាប់យកទៅគិតគូរធ្វើ CBPMS ជាថ្មីក្នុងតំបន់ឯទៀត ។ សិក្ខាសាលាថ្នាក់ជាតិ បានផ្ដល់លទ្ធផលជាការបង្កើតក្រុមការងារបច្ចេកទេសខាងការសំគាល់រកមើលគ្រួសារក្រីក្រដែលដឹកនាំដោយក្រសួងផែនការ ។

វិជ្ជាស្ថានជាតិស្ថិតិ បានបង្ហាញពីការយកចិត្តទុកដាក់ខ្លាំងចង់កែសំរួល CBPMS និងពង្រីកវាជាបណ្ដើរៗទៅទូទាំងប្រទេស ។ ប៉ុន្តែដោយកង្វះធនធាន និងសមត្ថភាព សព្វថ្ងៃមិនទាន់មានប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមដែលអាចធ្វើការគ្រប់គ្រង និងចាត់ចែងទិន្នន័យទេ ។ NIS បានទទួលការឧបត្ថម្ភពីអ្នកផ្ដល់ជំនួយជាច្រើន ហើយអាចចាប់អនុវត្តគំនិតផ្ដួចផ្ដើមនេះ បើសិនបានទទួលទុនចាប់ផ្ដើមច្រើនទៀត ពីបណ្ដាញប្រព័ន្ធតាមដានផ្អែកលើសហគមន៍អន្តរជាតិ ។ ឆ្លងតាមបទពិសោធន៍ដ៏មានតំលៃនៃគំរោងនេះ វបសអ អាចបំពេញតួនាទីជាសមាជិកសកម្មនៃបណ្ដាញ ដើម្បីជំរុញការចំលងតាម និងការពង្រីកCBPMS ។ ដូច្នេះជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីខាងក្រៅសំរាប់ NIS មានសារៈសំខាន់ជាគន្លឹះដើម្បីជំរុញគំនិតផ្ដួចផ្ដើមនេះឱ្យទៅមុខ ។

# តារាងជានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចំនួនគំរោងវិនិយោគ* | | | | | | |
| សរុប | 300 | 136 | 140 | 96 | 96 | 188 | 37 | 15 | 15 | 19 | 20 | 11 |
| កាត់ដេរ | 144 | 48 | 84 | 44 | 52 | 76 | 15 | 6 | 11 | 9 | 11 | 9 |
| | | | | | | មូលធនបានចុះបញ្ជី (លានដុល្លារ) | | | | | | |
| សរុប | 391.2 | 278.0 | 416.4 | 246.8 | 102.4 | 129.2 | 48.9 | 15.4 | 11.9 | 10.0 | 23.0 | 10.0 |
| កាត់ដេរ | 156.8 | 34.4 | 91.6 | 55.6 | 25.6 | 60.0 | 12.6 | 5.8 | 8.4 | 1.0 | 13.5 | 8.0 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| សរុប | 746.8 | 761.6 | 849.2 | 474.0 | 266.4 | 217.2 | 239.6 | 62.1 | 63.3 | 113.3 | 82.0 | 16.4 |
| កាត់ដេរ | 158.4 | 38.8 | 120.8 | 79.6 | 76.8 | 100.0 | 18.0 | 14.5 | 49.9 | 10.1 | 44.0 | 12.7 |

*ប្រភព: ក្រុមប្រឹក្សាវិនិយោគកម្ពុជា (១៩៩៥-២០០៣) ។ * ក្នុងនេះមានទាំងគំរោងពង្រីកគំរោងវិនិយោគដែលមានស្រាប់ ។*

## តារាង២. គំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ភូមិគ្រឹះ | 205 | 179 | 143 | 136 | 111 | 108 | 159 | 48 | 52 | 47 | 57 | 37 |
| ផ្ទះល្វែង | 537 | 528 | 678 | 864 | 520 | 499 | 535 | 116 | 157 | 161 | 186 | 125 |
| ផ្សេងៗ | 116 | 117 | 132 | 74 | 64 | 57 | 75 | 22 | 20 | 29 | 33 | 27 |
| សរុប | 858 | 824 | 953 | 1074 | 695 | 664 | 769 | 186 | 229 | 237 | 276 | 189 |

*ប្រភព: នាយកដ្ឋានសិយោជី និងភូមិសាស្ត្រ ក្រុងភ្នំពេញ ។*

## តារាង៣. ការនាំចេញ និងនាំចូល ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 387.1 | 493.4 | 784.4 | 941.1 | 1055.5 | 1267.0 | 1453.7 | 475.7 | 399.5 | 494.7 | 668.8 | 545.1 |
| រួមមាន: - សំលៀកបំពាក់ | 78.8 | 227.2 | 378.0 | 554.0 | 962.1 | 1201.0 | 1356.2 | 448.5 | 383.6 | 479.4 | 643.7 | 520.3 |
| ទៅសហរដ្ឋអាមេរិក | 0.4 | 107.2 | 74.1 | 486.0 | 714.1 | 840.9 | 943.8 | 298.2 | 255.8 | 306.3 | 387.6 | 321.2 |
| ប្រទេសផ្សេងទៀត | 78.4 | 120.0 | 82.0 | 68.0 | 248.0 | 360.1 | 412.4 | 150.3 | 127.8 | 173.1 | 256.1 | 199.1 |
| - កសិកម្ម | - | - | - | - | 90.5 | 66.0 | 97.5 | 27.2 | 16.0 | 15.3 | 25.1 | 24.8 |
| កៅស៊ូ | - | - | - | - | 29.6 | 25.9 | 29.7 | 12.1 | 8.0 | 6.6 | 11.6 | 12.0 |
| ឈើ | - | - | - | - | 32.5 | 22.3 | 16.0 | 2.4 | 1.8 | 2.8 | 4.2 | 2.4 |
| ជលផល | - | - | - | - | 5.4 | 6.0 | 4.3 | 0.7 | 0.8 | 1.2 | 4.3 | 4.4 |
| ផ្សេងៗ | - | - | - | - | 26.0 | 11.8 | 47.5 | 12.0 | 5.4 | 4.8 | 5.0 | 6.0 |
| ការនាំចូលសរុប | 1114.4 | 1094.5 | 1112.2 | 1237.4 | 1417.7 | 1501.4 | 1674.1 | 487.6 | 458.8 | 607.0 | 528.0 | 548.5 |
| រួមមាន: សាំង | - | - | - | - | - | - | 26.0 | 9.0 | 7.1 | 8.6 | 6.6 | 7.8 |
| ម៉ាស៊ីត | - | - | - | - | - | - | 102.0 | 24.5 | 30.4 | 27.7 | 27.4 | 23.6 |
| សំភារៈសំណង់ | - | - | - | - | - | - | 97.4 | 21.6 | 20.2 | 27.0 | 21.3 | 26.5 |
| ផ្សេងៗ | - | - | - | - | - | - | 1448.7 | 432.5 | 401.1 | 543.6 | 472.7 | 490.6 |
| ជញ្ជីងពាណិជ្ជកម្ម | -727.3 | -601.2 | -327.8 | -296.3 | -362.2 | -234.0 | -220.4 | -11.9 | -59.3 | -112.2 | 140.8 | -3.4 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 198.0 | 188.0 | 66.0 | 47.0 | 74.0 | 24.8 | 12.9 | 16.4 | 21.9 | 23.0 | 35.4 | 16.0 |
| ការនាំចេញសរុប | 2.1 | 27.5 | 58.9 | 12.4 | 19.7 | 20.0 | 14.7 | 15.2 | 20.5 | 21.1 | 35.8 | 14.6 |
| ការនាំចូលសរុប | 1.2 | -1.8 | 1.6 | 11.3 | 14.5 | 5.9 | 11.5 | 19.6 | 16.5 | 19.6 | 21.0 | 12.5 |

*ប្រភព: ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, ទីចាត់ការគយ និងរដ្ឋាករ.*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៦-២០០៤

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | អ្នកដំណើរពាន់នាក់ | | | | | | |
| ទិដ្ឋាការទេសចរ | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 447.4 | 201.8 | 230.7 | 165.3 | 203.1 | 281.5 |
| តាមផ្លូវអាកាស | 194.4 | 163.0 | 141.9 | 199.6 | 209.6 | 335.4 | 447.4 | 129.4 | 139.6 | 99.6 | 125.1 | 179.3 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 72.4 | 91.1 | 65.8 | 78.0 | 102.2 |
| ទិដ្ឋាការជំនួញ | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 58.3 | 15.2 | 15.8 | 20.8 | 17.2 | 19.0 |
| តាមផ្លូវអាកាស | 58.4 | 48.6 | 37.6 | 55.4 | 46.9 | 62.4 | 58.3 | 10.5 | 11.5 | 16.9 | 12.4 | 13.5 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 4.6 | 4.3 | 3.9 | 4.8 | 5.5 |
| ទិដ្ឋាការរដ្ឋការ | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 17.3 | 5.7 | 7.9 | 7.6 | 7.8 | 10.5 |
| តាមផ្លូវអាកាស | 7.6 | 7.2 | 6.8 | 7.9 | 95.2 | 10.6 | 17.3 | 5.0 | 6.8 | 6.3 | 6.4 | 8.7 |
| តាមផ្លូវគោក និងទឹក | - | - | - | - | - | - | - | 0.7 | 1.1 | 1.3 | 1.4 | 1.7 |
| សរុបតាមផ្លូវអាកាស | | | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 145.0 | 157.9 | 122.8 | 143.9 | 201.5 |
| សរុបតាមផ្លូវគោក និងទឹក | - | - | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 77.7 | 96.5 | 71.0 | 84.2 | 109.5 |
| សរុបអ្នកដំណើរ | 260.4 | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 222.7 | 254.4 | 193.8 | 228.1 | 311.0 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុបអ្នកដំណើរ | 18.5 | -15.9 | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -2.6 | 21.8 | 74.5 | 44.0 | 39.6 |

*ប្រភព: ក្រសួងទេសចរណ៍ ។*

## តារាង៥. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៦-២០០៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | - | - | - | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 4.6 | 7.9 | 22.1 | 23.0 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 7.1 | 8.0 | 14.8 | 4.0 | -0.8 | -0.6 | 3.3 | 0.5 | 0.8 | 2.2 | 6.7 | 5.8 |
| - ម្ហូបអាហារ | 7.6 | 6.7 | 14.1 | 7.6 | -3.3 | -2.8 | 1.8 | -0.04 | 0.6 | 3.4 | 12.2 | 9.1 |
| - ថាមពល | 20.7 | 20.0 | 15.1 | 3.5 | 6.6 | -1.1 | 0.3 | 5.1 | 4.8 | 8.1 | 11.5 | 14.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | - | - | - | - | 3,840.8 | 3,916.3 | 3,912.1 | 3,987.0 | 3,990.3 | 4,005.3 | 4,034.7 | 4,034.7 |
| រៀលក្នុង ១ បាតថៃ | - | - | - | - | 95.8 | 88.2 | 91.2 | 100.4 | 102.0 | 99.6 | 97.7 | 100.1 |
| រៀលក្នុង ១០០ ដុងវៀតណាម | - | - | - | - | 27.1 | 26.6 | 25.6 | 25.5 | 25.4 | 25.4 | 24.8 | 25.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 34.0 | 33.3 | 32.7 | 36.8 | 44.4 | 46.0 | 46.0 | 46.3 | 47.0 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,508 | 1,700 | 1,867 | 1,983 | 2,150 | 2,350 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,150 | 2,400 | 2,567 | 2,767 | 2,950 | 3,050 |

## តារាង ៦. ស្ថានភាពរូបិយវត្ថុ ១៩៩៦-២០០៤ (ចុងការិយបរិច្ឆេទ)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 881 | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,737 | 4,027 | 4,265 | 4,337 | 4,524 | 4,797 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 31 | -114 | -496 | -576 | -759 | -876 | -849 | -698 | -606 | -493 | -354 | -467 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 128 | 54 | 178 | 103 | 3 | -75 | -119 | -128 | -133 | -130 | -96 | -209 |
| ឥណទានចំពោះផ្នែកឯកជន | 435 | 637 | 655 | 763 | 898 | 936 | 1,059 | 1,337 | 1,389 | 1,499 | 1,673 | 1,817 |
| រូបិយវត្ថុទូទៅ M2 | 912 | 1,063 | 1,230 | 1,443 | 1,831 | 2,204 | 2,888 | 3,328 | 3,659 | 3,844 | 4,169 | 4,329 |
| រូបិយវត្ថុ M1 | 329 | 385 | 543 | 531 | 540 | 609 | 813 | 937 | 1,007 | 1,040 | 1,078 | 1,153 |
| រូបិយវត្ថុផ្សេងៗ | 583 | 678 | 687 | 911 | 1,291 | 1,594 | 2,075 | 2,391 | 2,652 | 2,804 | 3,091 | 3,176 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 40.3 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 21.8 | 30.2 | 38.7 | 30.0 |
| រូបិយវត្ថុ M1 | 18.3 | 17 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 21.5 | 17.4 | 21.7 | 23.0 |
| រូបិយវត្ថុផ្សេងៗ | 57.1 | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 21.9 | 36.7 | 45.8 | 32.8 |

## តារាង៧. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ១៩៩៦-២០០៤ (ពាន់លានរៀល)

| | 1996 | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 Q4 | 2004 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 748 | 880 | 920 | 1326 | 1528 | 1529 | 1744 | 557 | 523.9 | 488.5 | 452.1 | 662.2 |
| ចំណូលចរន្ត | - | - | - | - | - | 1521 | 1728 | 557 | 523.3 | 475.5 | 450.8 | 657.7 |
| ចំណូលពន្ធ | 536 | 596 | 676 | 956 | 1096 | 1096 | 1227 | 387 | 409.3 | 348.4 | 334.1 | 485.7 |
| ពន្ធគយ | 344 | 348 | 376 | 432 | 376 | 376 | 424 | 117 | 137.0 | 108.4 | 99.9 | 168.0 |
| ចំណូលមិនមែនពន្ធ | 176 | 272 | 204 | 348 | 424 | 424 | 501 | 170 | 113.9 | 127.1 | 116.7 | 172.1 |
| អាជីវកម្មព្រៃឈើ | 28 | 36 | 20 | 36 | 28 | 29 | 15 | 1 | 0.9 | 0.3 | 0.2 | 0.5 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 64 | 84 | 88 | 108 | 124 | 122 | 123 | 50 | 16.1 | 23.1 | 28.8 | 26.3 |
| ចំណូលជាមូលធន | 40 | 12 | 36 | 12 | 8 | 9 | 16 | 0 | 0.6 | 13.0 | 1.3 | 4.5 |
| ចំណាយសរុប | 1440 | 1260 | 1296 | 1792 | 2332 | 2332 | 2948 | 746 | 668.1 | 710.6 | 703.4 | 909.3 |
| ចំណាយជាមូលធន | 628 | 452 | 368 | 624 | 976 | 977 | 1388 | 306 | 316.6 | 337.1 | 277.3 | 293.5 |
| ចំណាយចរន្ត | 812 | 808 | 980 | 1164 | 1356 | 1355 | 1560 | 440 | 351.5 | 373.4 | 426.0 | 615.8 |
| អប់រំ និងសុខាភិបាល | 124 | 128 | 132 | 280 | 344 | 343 | 454 | 227 | 31.4 | 80.6 | 116.0 | 290.0 |
| ការពារជាតិ និងសន្តិសុខ | 408 | 420 | 448 | 464 | 404 | 405 | 438 | 147 | 67.6 | 66.0 | 91.5 | 197.8 |
| ក្រសួងផ្សេងៗទៀត | 284 | 260 | 332 | 412 | 636 | 637 | 668 | 65 | 77.4 | 140.8 | 183.2 | 403.4 |
| ឱនភាពជាទូទៅ | -692 | -380 | -380 | -476 | -804 | -803 | -1204 | -189 | -144.2 | -222.1 | -251.2 | -247.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 680 | 444 | 268 | 416 | 768 | 766 | 1249 | 295 | 231.2 | 238.5 | 216.6 | 238.7 |
| ហិរញ្ញប្បទានក្នុងស្រុក | 12 | -64 | 112 | 60 | 36 | 37 | -45 | -106 | -87.0 | -16.5 | 34.6 | 8.4 |

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមរបស់ពលករងាយរងគ្រោះ (គិតតាមក៏រិតថ្លៃថេរនៅខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1998 | 2000 | 2003 | | 2004 | | | | 2005 | 2004 | | 2005 |
| | កុម្ភៈ | វិច្ឆិកា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | សីហា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 10,063 | 7,594 | 9,074 | 9,494 | 9,153 | 8,000 | 7,631 | 5,670 | 8,529 | -15.9% | -40.3% | -6.8% |
| អ្នកលីសែង | 7,636 | 6,233 | 7,006 | 6,286 | 8,383 | 7,451 | 6,625 | 5,121 | 6,933 | -5.4% | -18.5% | -17.3% |
| អ្នកលក់បន្លែតូចតាច | 5,695 | 5,256 | 6,635 | 6,480 | 7,130 | 7,240 | 6,650 | 7,767 | 6,385 | 0.2% | 4.4% | -10.4% |
| អ្នករើសអេតចាយ | 3,776 | 2,718 | 4,749 | 3,772 | 4,625 | 4,368 | 4,769 | 4,024 | 5,382 | 0.4% | 6.7% | 16.4% |
| អ្នកបំរើតាមភោជនីយដ្ឋាន* | – | 2,111 | 4,374 | 4,289 | 4,721 | 4,273 | 4,591 | 4,207 | 4,470 | 5.0% | -1.9% | 16.3% |
| អ្នកស៊ីឈ្នួលធ្វើស្រែ | – | 4,184 | 5,347 | 4,801 | 5,124 | 4,002 | 3,689 | 3,740 | 3,578 | -10.8% | -8.6% | 30.3% |
| កម្មកររោងចក្រកាត់ដេរ | – | 6,701 | 9,962 | 9,671 | 9,322 | 9,249 | 9,211 | 9,328 | 9,213 | -7.5% | -3.5% | -1.2% |
| អ្នករត់ម៉ូតូឌុប | – | 8,610 | 10,542 | 9,671 | 10,791 | 8,546 | 8,791 | 8,688 | 11,767 | -16.6% | -10.2% | 9.0% |
| កម្មករសំណង់គ្មានជំនាញ | – | 5,399 | 7,369 | 5,996 | 6,937 | 6,552 | 6,095 | 5,944 | 5,747 | -17.3% | -0.9% | -17.2% |
| កម្មករសំណង់មានជំនាញ | – | 13,127 | 12,283 | 16,344 | 13,297 | 11,822 | 13,527 | 12,071 | 14,367 | 10.1% | -26.1% | 8.0% |

*សំគាល់: ចំនួលអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំណង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។ *ចំនួលអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្តល់ឱ្យទេ ។ ប្រភព: តារាង៥: វបសអ, IMF, NBC, NIS ក្រសួងផែនការ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / តារាង៦: ធនាគារជាតិនៃកម្ពុជា *Q4 2003 បានកែតំរូវ / តារាង៧: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទិន្នន័យសំរាប់ Q1-Q4 2004 បានកែតំរូវ/ តារាង៨: វបសអ ។*

តពីទំព័រ ១៦

# ពត៌មានថ្មីៗពី...

ក្រុមស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្ម បានបោះផ្សាយការសិក្សាសំខាន់មួយស្តីពីសេដ្ឋកិច្ចឆ្លងកាត់ព្រំដែននៅក្នុងតំបន់ ដែលជាចំណែកមួយនៃការចូលរួមជាបន្តនៅក្នុងបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ។ នាពេលថ្មីៗមូលនិធិ Rockefeller បានយល់ព្រមពង្រីកជំនួយទ្រទ្រង់របស់ខ្លួន ដល់ការសិក្សាពីរបន្ថែមទៀតនៅក្នុងតំបន់ ។ ក្រៅពីនេះ ក៏មានគំនិតផ្តួចផ្តើមថ្មីៗជាច្រើនទៀតស្តីពីការស្រាវជ្រាវពីពាណិជ្ជកម្មក្នុងតំបន់ ដែលកំពុងស្ថិតនៅក្នុងដំណាក់កាលតាក់តែងរចនា ។ ការវិវត្តន៍ទាំងនេះបានបង្ហាញថា វបសអកំពុងបង្កើនការស្រាវជ្រាវរបស់ខ្លួន ដែលទាក់ទិននឹងពាណិជ្ជកម្មក្នុងតំបន់ ។ ដោយឡែកក្រុមស្រាវជ្រាវសេដ្ឋកិច្ច និងពាណិជ្ជកម្ម បានបន្តធ្វើរបាយការណ៍យ៉ាងទៀងទាត់ស្តីពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា ។

ក្រុមស្រាវជ្រាវអភិបាលកិច្ច និងវិមជ្ឈការ បានកសាងរបាយការណ៍ដ៏មានគុណភាពមួយចំនួន ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការកែទំរង់វិស័យសាធារណៈនៅកម្ពុជា និងដែលមានជាអាទិ៍ អង្កេតតាមដានចំណាយសាធារណៈ (PETS) និងការផ្តត់ផ្គង់សេវាមូលដ្ឋាន ។ ក្រុមស្រាវជ្រាវ កំពុងតាក់តែងរចនាការផ្តួចផ្តើមគំនិតស្រាវជ្រាវថ្មីធំៗពីរទៀតគឺ ទី១ ផ្តោតលើគណនេយ្យភាពនៃវិស័យសាធារណៈនៅកំរិតខេត្ត និងទី២ ផ្តោតលើការឆ្លើយតបរបស់វិស័យសាធារណៈ ។

ក្រុមស្រាវជ្រាវធនធានធម្មជាតិ និងបរិស្ថាន (NRE) សព្វថ្ងៃមានកំលាំងពេញលេញហើយដោយមានទីប្រឹក្សាបច្ចេកទេស ១នាក់ និងអ្នកស្រាវជ្រាវកម្ពុជាពេញម៉ោង ២នាក់ ។ ក្រុម NRE ទើបបានបញ្ចប់ជុំដំបូងនៃការចុះសិក្សាដល់កន្លែងក្នុងខេត្តមណ្ឌលគិរី និងក្រចេះ ស្តីពីការកំណត់តំលៃធនធានព្រៃឈើ ។ នាពេលថ្មីៗ ក្រុម NRE បានទទួលទស្សនកិច្ចរបស់អ្នកស្រាវជ្រាវពីររូបនៃមជ្ឈមណ្ឌលដាណឺម៉ាក សំរាប់ព្រៃឈើ ទេសភាព និងផែនការ ដែលមករកមើលលទ្ធភាពធ្វើសហការខាងអភិបាលកិច្ច និងការដោះស្រាយទំនាស់ក្នុងវិស័យព្រៃឈើ ។ នៅដើមខែកក្កដា តំណាងមួយក្រុមមកពីសាកលវិទ្យាល័យស៊ីដនី បានធ្វើទស្សនកិច្ចនៅ វបសអ ដើម្បីពិនិត្យពីសក្តានុពលសំរាប់កិច្ចសហការស្រាវជ្រាវ និងការកសាងសមត្ថភាពការស្រាវជ្រាវពីគោលនយោបាយធនធានទឹក ។

វបសអ ក៏សហការផងដែរជាមួយបណ្តាញស្រាវជ្រាវ និងបណ្តុះបណ្តាលពីពាណិជ្ជកម្មនៅអាស៊ីប៉ាស៊ីហ្វិក (ARTNeT) និង UN/ESCAP ដើម្បីធ្វើអង្កេតនិងកំណត់ពីតំរូវការកសាងសមត្ថភាពខាងការស្រាវជ្រាវពីពាណិជ្ជកម្មអន្តរជាតិ នៅក្នុងស្ថាប័នស្រាវជ្រាវនានានៃបណ្តាប្រទេសអភិវឌ្ឍន៍តិចបំផុតនិងប្រទេសកំពុងអភិវឌ្ឍន៍មានចំនូលទាប នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ។ វបសអ ក៏សហការផងដែរជាមួយវិជ្ជាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ លើគំរោងស្រាវជ្រាវពីរគឺ PPA ដូចបញ្ជាក់ខាងលើ និងផលប៉ះពាល់លើភាពក្រីក្រនៃសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៅក្នុងមហាអនុតំបន់មេគង្គ ។ ក្នុងពេលជាមួយគ្នា វបសអ មានផែនការពង្រីកគំរោងអង្កេតមូលដ្ឋានលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីក្នុងតំបន់ទីក្រុង ដោយរួមសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ វបសអ ក៏បានបង្កើនចំនួនមុខនៃកិច្ចសហការជាលក្ខណៈស្ថាប័នផងដែរ ។ ឧទាហរណ៍ វបសអ បានចូលរួមក្នុងគំរោងស្រាវជ្រាវខ្នាតតូចជាច្រើន ជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ FAO (ការវាយតំលៃមូលដ្ឋានទិន្នន័យលើការកាន់កាប់ដី) និងបានដាក់សំណើស្រាវជ្រាវមួយទៅអង្គការអុកស្វាមអាមេរិក (ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ចិន-អាស៊ាន ទៅលើកសិកម្មកម្ពុជា) ។

## មជ្ឈមណ្ឌលដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (មសអ)

ពីខែមករា-មិថុនា ២០០៥ សកម្មភាព មសអ ផ្តោតជាសំខាន់លើការបណ្តុះបណ្តាល ជាពិសេសការបណ្តុះបណ្តាលតាមកិច្ចសន្យា សំរាប់អង្គការ GTZ និង terre des hommes ។ ការបណ្តុះបណ្តាលតាមកិច្ចសន្យាមាន ៤ម៉ូឌុល (មួយម៉ូឌុលមាន ៥ថ្ងៃ) និងមានចំណងជើងថា "រួមគ្នាធ្វើការដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងវគ្គបណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល" ដែលត្រូវបានតាក់តែងរៀបចំសំរាប់ដៃគូ ៣២នាក់ របស់ GTZ នៅខេត្តកំពង់ធំ បានចប់សព្វគ្រប់នៅខែកុម្ភៈ ។ វគ្គ "ការបម្លែងទំនាស់ និងការកសាងសន្តិភាព" ត្រូវបានតាក់តែងរៀបចំសំរាប់ដៃគូ ២៥នាក់របស់ terre des hommes នៅភ្នំពេញ និងបានដំណើរការនៅខែឧសភា ។ វគ្គបណ្តុះបណ្តាលដើម្បីសន្តិភាពឆ្នាំ២០០៥ ដែលបានផ្តល់តែចំពោះអ្នកដែលបានបញ្ចប់វគ្គ "រួមគ្នាធ្វើការដើម្បីសន្តិភាព" បានចប់សព្វគ្រប់នៅខែមេសា ២០០៥ ហើយវគ្គបំពេញបន្ថែមមួយទៀតនឹងធ្វើឡើងនៅឆមាសក្រោយ ។ នៅខែមេសា មសអ បានធ្វើការវាយតំលៃពីតំរូវការបណ្តុះបណ្តាលសំរាប់ស្រុកបវេល ខេត្តបាត់ដំបង បន្ទាប់មកមានការតាក់តែងរៀបចំវគ្គពិសេសមានរយៈ ៦ថ្ងៃ ២វគ្គ ឈ្មោះថា "រួមគ្នាធ្វើការដើម្បីសន្តិភាព និងអភិវឌ្ឍន៍" ដែលបានដំណើរការនៅខែឧសភា និងមិថុនា សំរាប់សិក្ខាកាម ៥២នាក់ មកពីក្រុមប្រឹក្សាឃុំ ចំនួន ៦ ព្រមទាំងអាជ្ញាធរនៅស្រុកបវេល ។ ម្យ៉ាងទៀត បានដំណើរការផងដែរនូវវគ្គបណ្តុះបណ្តាលដើម្បីសន្តិភាពឆ្នាំ២០០៥ ម៉ូឌុល១ (មួយវគ្គមាន ៤ម៉ូឌុល និងមួយម៉ូឌុលមាន ៥ថ្ងៃ) នៅ វបសអ សំរាប់សិក្ខាកាម ២៥នាក់ ។

## បណ្ណាល័យ

បណ្ណាល័យ វបសអ ប្រើប្រាស់សូហ្វវែរ WINISIS សំរាប់គ្រប់គ្រង សៀវភៅ និងឯកសាររបស់ខ្លួន ។ មូលដ្ឋានទិន្នន័យមានចុះជាង ៩.000កំណត់ត្រា ។ អ្នកប្រើប្រាស់បណ្ណាល័យអាចស្រាវជ្រាវក្នុងកាតាឡុក រកតាមចំណងជើង អ្នកនិពន្ធ គ្រឹះស្ថានបោះពុម្ពផ្សាយ រឺពាក្យគន្លឹះ ។ ម្យ៉ាងទៀត អ្នកប្រើប្រាស់អាចស្រាវជ្រាវលំអិត តាមប្រទេស និងតាមឆ្នាំបោះពុម្ពផ្សាយ, ដើម្បីរកបានឯកសារថ្មីបំផុត និងជាប់ទាក់ទងល្អបំផុតនៅក្នុងបណ្ណាល័យ ។

បណ្ណាល័យ វបសអ បានអញ្ជើញនាយបណ្ណាល័យធំៗនៅភ្នំពេញ មកពិភាក្សាពីវិធីកសាងបណ្តាញបណ្ណាល័យនៅកម្ពុជា ជាពិសេស បញ្ហាបង្កើតសាលាបង្រៀនជំនាញបណ្ណាល័យ ដើម្បីកែលំអគុណភាពបណ្ណារក្សកម្ពុជា ។

បណ្ណាល័យ វបសអ ឥឡូវនេះមានលទ្ធភាពស្វែងរកបានយ៉ាងទូលាយនូវព័ត៌មានស្រាវជ្រាវខាងកសិកម្ម តាមរយៈប្រព័ន្ធស្រាវជ្រាវសាកលខាងកសិកម្មតាមអ៊ិនធឺណិត (AGORA) ។ បណ្ណាល័យបានប្រគល់ភារៈឱ្យលោកស្រី សុខ សិទ្ធា ទៅទទួលការបណ្តុះបណ្តាលពីរបៀបប្រើប្រាស់មូលដ្ឋានទិន្នន័យនេះ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម នៅថ្ងៃទី ១៤ មីនា ។

មួយចំណែកទៀត លោក ហ៊ី ហ៊ិន បានបណ្តុះបណ្តាលបុគ្គលិកមួយចំនួននៅមជ្ឈមណ្ឌលធនធានសិក្សានៃធនាគារអភិវឌ្ឍន៍អាស៊ី ពីថ្ងៃទី ២៨ មីនា ដល់ ១ មេសា ២០០៥ ។

នៅថ្ងៃ ២០ មិថុនា ២០០៥ បណ្ណាល័យបានទទួលនិស្សិតមួយក្រុមមកពីរដ្ឋហាវ៉ៃ សហរដ្ឋអាមេរិក ។

# ពត៌មានថ្មីៗពី វបសអ



*អគារថ្មីរបស់ វបសអ នៅខ័ណ្ឌទួលគោក ភ្នំពេញ*

## ផ្នែកគ្រប់គ្រង

នៅខែមីនា-មេសា ២០០៥ ផ្នែកគ្រប់គ្រង វបសអ បានធ្វើទស្សនកិច្ចកសាងភាពជាដៃគូជាយុទ្ធសាស្ត្រ ទៅកាន់ប្រទេសអូស្ត្រាលី និងសិង្ហបុរី ដើម្បីពិនិត្យរក និងពង្រឹងភាពជាដៃគូ សំរាប់កិច្ចសហការស្រាវជ្រាវ និងឱកាសអភិវឌ្ឍន៍ជំនាញ និងការអប់រំក្រោយថ្នាក់បរិញ្ញាប័ត្ររបស់បុគ្គលិក វបសអ ។ នៅថ្ងៃអនាគត វបសអ នឹងធ្វើការកាន់តែជិតស្និទ្ធជាមួយស្ថាប័នមួយចំនួន ជាអាទិ៍ សាកលវិទ្យាល័យស៊ីដនី, សាលាអាស៊ី-ប៉ាស៊ីហ្វិកខាងសេដ្ឋកិច្ច និងរដ្ឋាភិបាលនៃសាកលវិទ្យាល័យជាតិអូស្ត្រាលី, ព្រមទាំងស្ថាប័នពីរទៀតនៅសិង្ហបុរី គឺវិទ្យាស្ថានសិក្សាពីអាស៊ីអគ្នេយ៍ និងសាលាគោលនយោបាយសាធារណៈ លី ក្វាន់យូ ។

ក្នុងខែមេសា ២០០៥ នៅមុនពេលបុណ្យចូលឆ្នាំខ្មែរ មានធ្វើពិធីសម្ពោធអគារថ្មីរបស់ វបសអ ក្រោមអធិបតីភាព ឯ.ឧ. ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាភិបាលនៃ វបសអ ។ អគារថ្មីមានបន្ទប់ដ៏ទូលាយមួយ សំរាប់ប្រជុំ និងធ្វើការបណ្តុះបណ្តាល ព្រមទាំងមានបន្ទប់ធ្វើការសំរាប់ក្រុមស្រាវជ្រាវ វបសអ ២ក្រុម គឺខាងភាពក្រីក្រ ការអភិវឌ្ឍន៍កសិកម្ម និងជីវភាពនៅជនបទ, និងខាងធនធានធម្មជាតិ និងបរិស្ថាន, ដែលមានការងារពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

នៅខែឧសភា ២០០៥ វបសអ បានចុះកិច្ចព្រមព្រៀងជាមួយកម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ (UNDP) ដើម្បីទ្រទ្រង់ដល់ដំណាក់កាលថ្មីមួយទៀតមានរយៈ ៣ឆ្នាំនៃការបង្ការទំនាស់ក្នុងដំនើរការបោះឆ្នោតនៅកម្ពុជា (COPCEL) ដែលនឹងចាប់ផ្តើមជាផ្លូវការនៅខែកក្កដា ២០០៥ ហើយបន្តរហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ដូច្នេះនឹងត្រូវធ្វើការងារភ្ជាប់នឹងការបោះឆ្នោតព្រឹទ្ធសភា ការបោះឆ្នោតឃុំសង្កាត់ និងការបោះឆ្នោតក៏រិតជាតិ ។

## ផ្នែកស្រាវជ្រាវ

អ្នកស្រាវជ្រាវទាំង ២ក្រុម ដែលកំពុងធ្វើការសិក្សាពី ការចាកផុតពីភាពក្រីក្រ (MOPS) និងការវាយតំលៃភាពក្រីក្រដោយមានការចូលរួម (PPA) បានជឿនលឿនការងារទៅមុខច្រើនណាស់ហើយ ។ ក្រុម MOPS កំពុងស្ថិតក្នុងដំណាក់កាលសរសេររបាយការណ៍ ក្រោយពីបានបញ្ចប់ការចុះសិក្សាដល់ភូមិចំនួន ៣វគ្គធំៗរួចហើយ រីឯក្រុម PPA បានបញ្ចប់ការងារនៅ ៣ខេត្ត ក្នុងចំណោមខេត្តត្រូវសិក្សាទាំង ៦ខេត្តនៅជុំវិញបឹងទន្លេសាប ។ ក្រុមទាំងពីរ កំពុងប្រឹងប្រែងវិភាគរកលទ្ធផលឱ្យបានទាន់ពេល ដើម្បីបញ្ចូលទៅក្នុងដំណើរការវាយតំលៃពីភាពក្រីក្រ ដែលសំរបសំរួលដោយធនាគារពិភពលោក ។ ការវាយតំលៃពីភាពក្រីក្រ នឹងផ្តល់ព័ត៌មានដល់រាជរដ្ឋាភិបាលក្នុងការធ្វើផែនការអភិវឌ្ឍន៍ជាតិសំរាប់ឆ្នាំ២០០៦-២០១០ ។

*តទៅទំព័រ ១៥*

**ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក៏មានផ្សាយជាភាសាអង់គ្លេសដែរ ៖**

***Cambodia Development Review*** **is also available in English.**

**ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា**

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

**ឆ្នាំទី៩ លេខ២ ខែមេសា_មិថុនា ឆ្នាំ២០០៥**

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*
បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង/មួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ ***អត្ថបទតាមដានសេដ្ឋកិច្ច*** ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

***ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា*** ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹង ត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh
website: http://www.cdri.org.kh

គ្រឹះស្ថានផ្សាយ: វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
គ្រប់គ្រងកែសំរួល: អែម សូវ៉ានី
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា /អ្នកបកប្រែ: យូ សិទ្ធីរិទ្ធ
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

**រក្សាសិទ្ធិ ២០០៥** វិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិកយន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560-7615**

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។